# នីតិព្រហ្មទណ្ឌ

ស្ដីពី

# នីតិព្រហ្មទណ្ឌពិសេស



រៀបចំដោយៈ សាស្ត្រាចារ្យ អ៊ិន សំអាត

Shared by Eang Samang

# សេចក្តីផ្តើម

នីតិព្រហ្មទណ្ឌ គឺសិក្សាទៅលើមុខវិជ្ជា នីតិព្រហ្មទណ្ឌទូទៅ នីតិព្រហ្មទណ្ឌពិសេសនិងនីតិវិធីព្រហ្មទណ្ឌ។ នីតិព្រហ្មទណ្ឌទូទៅ សិក្សាពីគោលការណ៍ទូទៅនៃច្បាប់ព្រហ្មទណ្ឌចាប់ពីមាត្រា១ ដល់មាត្រា១៨២ នៃក្រមព្រហ្មទណ្ឌ ដូចជា៖ គោលការណ៍ដែលទាក់ទងទៅនឹងការអនុវត្តច្បាប់ព្រហ្មទណ្ឌ បទល្មើសព្រហ្មទណ្ឌ ការទទួលខុសត្រូវព្រហ្មទណ្ឌ និងទោស ព្រមទាំងរបបនៃការប្រកាសទោស។ រីឯនីតិព្រហ្មទណ្ឌពិសេស ជាផ្នែកមួយនៃនីតិព្រហ្មទណ្ឌ ដែលសិក្សាអំពី ធាតុផ្សំបទល្មើស និងការកំណត់ឈ្មោះបទល្មើសនីមួយៗ ដែលមានចែងក្នុងច្បាប់ព្រហ្មទណ្ឌជាធរមាន(ក្រមព្រហ្មទណ្ឌ ) ។ ដោយនីតិព្រហ្មទណ្ឌពិសេស សិក្សាសំខាន់ទៅលើធាតុផ្សំបទល្មើស និងកំណត់ឈ្មោះបទល្មើស ដូចនេះដើម្បី ងាយស្រួលក្នុងការសិក្សា នៅក្នុងសេចក្តីផ្តើម យើងត្រូវស្វែងយល់អំពី សញ្ញាណទូទៅនៃនីតិព្រហ្មទណ្ឌ។

## ១-សញ្ញាណទូទៅនៃបទល្មើស

### ១.១.បទល្មើស

តាមក្រមព្រហ្មទណ្ឌកម្ពុជាចាស់ ត្រង់មាត្រា ១ បានចែងថា"ច្បាប់បញ្ញត្តថា អំពើខ្លះរបស់មនុស្ស ត្រូវចាត់ទុកថាជាបទល្មើស ហើយបទល្មើសនេះ ត្រូវតែបានទទួលទោស ដោយហេតុថា បទល្មើសនោះ អាចនឹងធ្វើឲ្យសង្គមមនុស្សកករល្អក់បាន"។

ដោយឡែក ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានបញ្ញត្តថា "អំពើខ្លះរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបង្កចលាចលដល់សង្គម ជាបទល្មើស"[1] ។

ចំណែកឯបណ្តាប្រទេសមួយចំនួន តាមរយៈច្បាប់ព្រហ្មទណ្ឌ បានកំណត់និយមន័យនៃបទល្មើស ថា "ជាអំពើដែលបង្កគ្រោះថ្នាក់ដល់សង្គម ត្រូវបានបញ្ញត្តក្នុង ច្បាប់ព្រហ្មទណ្ឌ បង្កឡើងដោយជនមាន សមត្ថភាពទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ដោយចេតនា ឬអចេតនា អំពើនេះបាន រំលោភបំពានលើឯករាជ្យភាព អធិបតេយ្យ ឯកភាពជាតិ និងបូរណភាពដែនដី របបសេដ្ឋកិច្ច កម្មសិទ្ធិរដ្ឋ បំពារបំពានលើអាយុជីវិត សុខភាព កិត្តិយស កេរ្តិ៍ឈ្មោះ សេរីភាព ទ្រព្យសម្បត្តិ និងសិទ្ធិ ប្រយោជន៍ស្របច្បាប់ខ្លះរបស់ពលរដ្ឋ បំពារបំពានលើវិស័យខ្លះ នៃសណ្តាប់ធ្នាប់នៃច្បាប់"។

ម្យ៉ាងវិញទៀត និយមន័យនៃពាក្យថាបទល្មើស ត្រូវបានកំណត់ដោយខ្លីថា "បទល្មើស ជាអំពើបង្កគ្រោះថ្នាក់ដល់សង្គម មានកំហុសផ្ទុយនឹងបញ្ញត្តិច្បាប់ព្រហ្មទណ្ឌ និងត្រូវបានទទួលការផ្តន្ទាទោស"។

### ១.២.ចរិតលក្ខណៈនៃបទល្មើស

គោលការណ៍សំខាន់នៃច្បាប់ព្រហ្មទណ្ឌ គឺការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ត្រូវបានដាក់បន្ទុកទៅលើជនណាដែលបានប្រព្រឹត្តនូវអំពើដែលមានចរិតគ្រោះថ្នាក់ដល់សង្គម។ បទល្មើសត្រូវតែជាអំពើរបស់មនុស្ស ។ ច្បាប់ពុំចាប់បង្ខំជនណាមួយឲ្យទទួលខុសត្រូវផ្នែក ព្រហ្មទណ្ឌ ដោយសារជននេះមាន គំនិត

[1] មាត្រា ២ វាក្យខណ្ឌទី ១ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

សតិអារម្មណ៍ល្មើសច្បាប់ ប្រសិនបើគំនិត ឬសតិអារម្មណ៍នោះពុំបានស្តែងចេញមក ខាងក្រៅតាមរយៈសកម្មភាពជាក់ស្តែងនៅឡើយ។

**ក.ចរិតគ្រោះថ្នាក់ដល់សង្គម**

ចរិតគ្រោះថ្នាក់ដល់សង្គមនៃបទល្មើស ស្តែងឡើងត្រង់ចំណុចថាអំពើនោះ បានបង្ក ឬគំរាម នឹងបង្កនូវការអន្តរាយ ដល់បណ្តាទំនាក់ទំនងសង្គមដែលច្បាប់ព្រហ្មទណ្ឌបានការពារ ។ ទំនាក់ទំនងសង្គមដែលច្បាប់ព្រហ្មទណ្ឌបានការពារ មានលក្ខណៈសំខាន់ វាជាបុព្វបទជានាឲ្យការរីកចម្រើនរបស់សង្គម។ ជារួម រាល់អំពើល្មើសច្បាប់រួមទាំង អំពើល្មើសនឹងសីលធម៌សង្គម សុទ្ធតែបង្ក ឲ្យមានគ្រោះថ្នាក់ដល់សង្គម ទោះបីតិច ឬច្រើន ប៉ុន្តែអ្នកតាក់តែងច្បាប់បាន ជ្រើសរើសអំពើបង្កគ្រោះថ្នាក់មួយចំនួនជាកំណត់ ដើម្បីបញ្ញត្តថាជាបទល្មើស ដូចនេះ នៅពេលដែលយើងនិយាយដល់ចរិតគ្រោះថ្នាក់ដល់សង្គមនៃបទល្មើសនោះ គឺយើងបានបកស្រាយ យកកម្រិតគ្រោះថ្នាក់ខ្ពស់ជាងការរំលោភលើសីលធម៌ ឬការរំលោភបំពានច្បាប់ផ្សេងៗ ទៀត ។ ចរិតបង្កគ្រោះថ្នាក់ដល់សង្គមនៃបទល្មើស ជាមូលដ្ឋានសម្រាប់ការបែងចែកបទល្មើស និងអំពើល្មើសផ្សេងទៀត ដែលមិនមែនជាបទល្មើស ម្យ៉ាងទៀតវាជាសំអាងសម្រាប់ការពិចារណា និងសម្រេចអំពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ កំណត់កម្រិតទោស ដែលត្រូវអនុវត្តទៅលើជនដែលបានប្រព្រឹត្ត អំពើល្មើសច្បាប់ព្រហ្មទណ្ឌ។

**ខ.ចរិតមានកំហុសនៃអំពើ**

អំពើដែលបង្កឲ្យមានគ្រោះថ្នាក់ដល់សង្គម ត្រូវបានចាត់ទុកថាជាជនល្មើស ប្រសិនបើការប្រព្រឹត្តធ្វើឡើងដោយចេតនា ឬអចេតនា ពោលគឺអំពើនោះត្រូវមានកំហុស ។ ក្នុងទ្រឹស្តីនៃច្បាប់ព្រហ្មទណ្ឌ កំហុសមានន័យថា "ដំណើរប្រព្រឹត្តផ្នែកផ្លូវចិត្ត របស់មនុស្សចំពោះ អំពើដែលបង្កឲ្យមានគ្រោះថ្នាក់ដល់សង្គមដែលប្រព្រឹត្តដោយជននោះ និងបច្ច័យដែលកើតឡើង ក្រោមរូបភាពចេតនា ឬអចេតនា។ មនុស្សពេលប្រព្រឹត្តអំពើបង្កគ្រោះថ្នាក់ ហើយត្រូវបានចាត់ទុកថាមានកំហុសប្រសិនបើសកម្មភាពនោះគឺជា លទ្ធផលដែលជននោះបានជ្រើសរើស និងសម្រេចដោយខ្លួនឯង ក្នុងស្ថានភាពដែលខ្លួនអាចជ្រើសរើស និងសម្រេចប្រព្រឹត្តនូវ អំពើណាមួយផ្សេងទៀតបាន ដើម្បីស្របនឹងប្រយោជន៍ ព្រមទាំងការកំណត់របស់សង្គម ឬតាមការកំណត់របស់ច្បាប់។

ឧទាហរណ៍៖ ក្រមព្រហ្មទណ្ឌបានបញ្ញត្តថា អំពើដកហូត ដោយទុច្ចរិត នូវទ្រព្យសម្បត្តិរបស់អ្នកដទៃតាមគ្រប់មធ្យោបាយក្នុងគោលបំណងយកធ្វើជាកម្មសិទ្ធិរបស់ខ្លួន គឺជាបទលួច[2] ។ មនុស្សអាចមានវិធីផ្សេងទៀតដើម្បីឲ្យបានទ្រព្យសម្បត្តិ ហើយពុំផ្ទុយនឹងប្រយោជន៍សង្គម ឬផ្ទុយច្បាប់ ដូចជា លក់ដូរ សេវា ជាដើម ។ កំហុសជាសញ្ញាណមួយនៃបទល្មើស ហើយត្រូវបានកំណត់ថាជាគោលការណ៍ មួយនៃច្បាប់ព្រហ្មទណ្ឌ ។ គេពុំអាចបង្ខំឲ្យជនណាម្នាក់ទទួលទោសដោយសារអំពើ បង្កគ្រោះថ្នាក់ដល់សង្គម

[2] មាត្រា ៣៥៣ នៃក្រមព្រហ្មទណ្ឌ

ដោយពុំបានពិនិត្យពិចារណា ដល់កំហុសនៃជននោះឡើយ។

**គ.ចរិតផ្ទុយច្បាប់ព្រហ្មទណ្ឌ**

អំពើដែលត្រូវបានចាត់ទុកថាជា បទល្មើស ប្រសិនបើអំពើនោះមានចរិត គ្រោះថ្នាក់ដល់សង្គម មានកំហុស និងត្រូវបានបញ្ញត្តក្នុង ច្បាប់ព្រហ្មទណ្ឌ។ នៅពេលដែលច្បាប់ ពុំបានចែងថាអំពើណាមួយ ជាបទល្មើសនោះពុំអាចធ្វើការចោទប្រកាន់ ឬផ្តន្ទាទោសជនដែលបានប្រព្រឹត្តអំពើនោះបានឡើយ។ នេះជាទស្សនៈជឿនលឿនមួយស្របនឹង ទិសដៅនីត្យានុកូលភាព ។ កំណត់ឲ្យបាននូវចរិតផ្ទុយច្បាប់នៃបទល្មើស អាចឲ្យយើងជានាបាននូវសិទ្ធិសេរីភាព ផលប្រយោជន៍ស្របច្បាប់របស់ពលរដ្ឋឲ្យរួចផុតពីការជំនុំជម្រះ ដោយលក្ខណៈធ្វេសប្រហែស ខ្ជីខ្ជា ពីសំណាក់ស្ថាប័នមានសមត្ថកិច្ច។

ដើម្បីអនុវត្តឲ្យបាននូវគោលការណ៍ "គ្មានទោស ប្រសិនបើគ្មានច្បាប់បញ្ញត្ត" នោះទាមទារឲ្យស្ថាប័នមានសមត្ថកិច្ច ក្នុងការងារកសាងច្បាប់ បំពេញបន្ថែមនូវបញ្ញត្តិច្បាប់ព្រហ្មទណ្ឌ ដើម្បីសមស្របតាម ការវិវឌ្ឍន៍នឹងស្ថានភាពនៃបទល្មើស និងស្របតាមការទាមទារឲ្យ ការពារនូវទំនាក់ទំនងសង្គមបញ្ចៀសផុតពីការបំផ្លិចបំផ្លាញនៃបទល្មើស ។ រាល់អំពើដែលបង្កឲ្យមានការអន្តរាយដល់សង្គម ត្រូវតែបានបង្រ្កាបដោយ វិធានការព្រហ្មទណ្ឌ ប៉ុន្តែការដោះស្រាយ វិនិច្ឆ័យរឿងក្តីព្រហ្មទណ្ឌ ត្រូវពឹងផ្អែកលើមូលដ្ឋានមានច្បាប់បញ្ញត្ត ។

**ឃ.ចរិតទទួលការផ្តន្ទាទោស**

ការចាប់បង្ខំ ឲ្យជនដែលបានប្រព្រឹត្ត នូវអំពើបង្កគ្រោះថ្នាក់ដល់សង្គម ឲ្យទទួល រងនូវការផ្តន្ទាទោស គឺជាវិធានការតឹងតែងបំផុតរបស់រដ្ឋ ។ការចាត់ទុកចរិតទទួលនូវការផ្តន្ទាទោស ជាសញ្ញាមួយនៃបទល្មើស បានស្តែងឲ្យឃើញថាការផ្តន្ទាទោស តែងផ្សារភ្ជាប់នឹងបទល្មើស ដែលជាប្រភេទអំពើរំលោភបំពានច្បាប់ បង្កឲ្យមានគ្រោះថ្នាក់ ធ្ងន់ធ្ងរដល់សង្គម ។ ក្នុងបណ្តាប្រភេទអំពើរំលោភបំពានច្បាប់ គឺមានតែបទល្មើសទេ ទើបនាំមកនូវបច្ច័យគតិយុត្ត គឺជនល្មើសត្រូវទទួលរងនូវការផ្តន្ទាទោស ។ ប្រការនេះពុំមានន័យថា គ្រប់ជនដែលបានប្រព្រឹត្តបទល្មើស សុទ្ធតែត្រូវបានទទួលរង នូវការផ្តន្ទាទោសនោះឡើយ ដូចជាក្នុងករណីដែលពុំអាចចាប់បង្ខំឲ្យទទួលរងនូវការផ្តន្ទាទោស នាពេលអាជ្ញាយុកាលនៃទោសបានផុតរលត់ ។ ចរិតទទួលការផ្តន្ទាទោសនៃបទល្មើស គឺជាសញ្ញាណមួយនៃបទល្មើស ប៉ុន្តែវាពុំពុំស្ថិតនៅក្នុងអង្គនៃបទល្មើសដូចចរិតគ្រោះថ្នាក់ កំហុសនិងចរិតផ្ទុយច្បាប់នៃបទល្មើសឡើយ។

## ២.ចំណាត់ថ្នាក់នៃបទល្មើស

ច្បាប់ព្រហ្មទណ្ឌ របស់បណ្តាប្រទេសមួយចំនួន បានបែងចែកបទល្មើសជាប្រភេទខុសៗគ្នាដោយផ្អែកលើ កម្រិតគ្រោះថ្នាក់ដល់សង្គមនៃបទល្មើស។

តាមក្រមព្រហ្មទណ្ឌរបស់ប្រទេសវៀតណាម បទល្មើសត្រូវបានបែងចែកជាពីរប្រភេទគឺបទល្មើសធ្ងន់ធ្ងរ និងបទល្មើសមិនធ្ងន់ធ្ងរ។បទល្មើសធ្ងន់ធ្ងរ គឺជាបទល្មើសដែលបង្កឲ្យមាន គ្រោះថ្នាក់ ការអន្តរាយធំធេងដល់សង្គម ហើយកម្រិតទោសសម្រាប់អំពើនេះ គឺលើសពី ៥ ឆ្នាំ ទោសគុក រហូតដល់ ២០ ឆ្នាំ ទោសគុក មួយជីវិត និងទោសប្រហារជីវិត ។ ចំណែកបទល្មើសមិនធ្ងន់ធ្ងរ នោះកម្រិតទោសគឺចាប់ពី ៥ ឆ្នាំ

ចុះ ឬប្រភេទទោស ស្រាលជាងទោសគុក ដូចជាព្រមាន ពិន័យជាប្រាក់ អប់រំដោយគ្មានការឃុំឃាំង ។

តាមទស្សនៈនៃក្រមព្រហ្មទណ្ឌកម្ពុជាចាស់ "បទល្មើសត្រូវបានបែងចែកជាបីប្រភេទគឺ បទឧក្រិដ្ឋ

បទមជ្ឈិមនិងបទលហុ។ការបែងចែកនេះផ្អែកទាំងស្រុងទៅលើទោសនៃបទល្មើសពោលគឺបទល្មើស ណាដែលត្រូវផ្តន្ទាទោសឧក្រិដ្ឋនោះ ត្រូវចាត់ទុកថាជាបទឧក្រិដ្ឋ បទល្មើសណាដែលត្រូវផ្តន្ទាទោសមជ្ឈិម ត្រូវចាត់ទុកថាជាបទមជ្ឈិម និងបទល្មើសណា ដែលត្រូវផ្តន្ទាទោសលហុ ត្រូវចាត់ទុកថាជាបទលហុ។ តាមក្រមព្រហ្មទណ្ឌកម្ពុជាចាស់នោះ បទល្មើសចែកជា៖

ផ្អែកតាមក្រមព្រហ្មទណ្ឌថ្មី បទល្មើសត្រូវបានកំណត់ជាបីថ្នាក់៖

**២.១.បទឧក្រិដ្ឋ**

សំដៅទៅលើ អតិបរមានៃទោសដាក់ពន្ធនាគារ ជាទោសដាក់ពន្ធនាគារអស់មួយជីវិតឬជាទោស ដាក់ពន្ធនាគារ មានកាលកំណត់ពី ៥ ឆ្នាំ រហូតដល់ ៣០ ឆ្នាំ និងទោសពិន័យជាប្រាក់[3] ។

បទឧក្រិដ្ឋមានអាជ្ញាយុកាលនៃបទល្មើស ១៥ ឆ្នាំ និងអាជ្ញាយុកាលនៃទោសរយៈពេល ២០ ឆ្នាំ។

**២.២.បទមជ្ឈិម**

សំដៅទៅលើអតិបរមានៃទោសដាក់ពន្ធនាគារមានរយៈពេលចាប់ពី ៦ ថ្ងៃ រហូតដល់ ៥ឆ្នាំនិង ទោសពិន័យជាប្រាក់[4]។ បទមជ្ឈឹមមានអាជ្ញាយុកាលនៃបទល្មើស ៥ ឆ្នាំ និងអាជ្ញាយុកាលនៃទោស រយៈពេល ៥ ឆ្នាំ។

**២.៣.បទលហុ**

សំដៅទៅលើអតិបរមានៃទោសដាក់ពន្ធនាគារមានរយៈពេលក្រោម ឬ ស្មើនឹង ៦ ថ្ងៃ ឬទោស ពិន័យជាប្រាក់សុទ្ធសាធ [5]។ បទលហុ មានអាជ្ញាយុកាលនៃបទល្មើស ១ ឆ្នាំ និងអាជ្ញាយុកាលនៃទោស រយៈពេល ១ ឆ្នាំ។

**៣.ធាតុផ្សំនៃបទល្មើស**

ដើម្បីកំណត់អំពើណាមួយ ជាបទល្មើសព្រហ្មទណ្ឌ លុះត្រាអំពើនោះមានធាតុផ្សំគ្រាប់គ្រាន់ ។ ធាតុផ្សំបទល្មើសមានបីគឺៈ

**៣.១.ធាតុនីត្យានុកូល ឬធាតុច្បាប់**

អំពើដែលបង្កើតជាបទល្មើស លុះតែអំពើនោះមានចែងក្នុងច្បាប់ព្រហ្មទណ្ឌជាធរមាន។ មានតែ ទោសដែលបានបញ្ញត្តិក្នុងច្បាប់ព្រហ្មទណ្ឌប៉ុណ្ណោះទើបអាចប្រកាសបាន។ គោលការណ៍ គ្មានបទល្មើស គ្មានទោស បើគ្មានច្បាប់ចែង (មាត្រា៣ ក្រមព្រហ្មទណ្ឌ)។

**៣.២.ធាតុសត្យានុម័ត ឬធាតុសំភារៈ**

[3] មាត្រា ៤៦ នៃក្រមព្រហ្មទណ្ឌ

[4] មាត្រា ៤៧ នៃក្រមព្រហ្មទណ្ឌ

[5] មាត្រា ៤៨ នៃក្រមព្រហ្មទណ្ឌ

ជាសកម្មភាព កាយវិការ ពាក្យសំដី រូបភាព ការប្រើឧបករណ៍ហាមឃាត់  ដែលអំពើនោះ ស្តែងឡើងក្រោមរូបភាពសកម្មក្តី អកម្មក្តី ហើយបង្កចលាចលដល់សង្គម (មាត្រា២ ក្រមព្រហ្មទណ្ឌ)។

**៣.៣.ធាតុអត្តនោម័ត ឬធាតុចិត្ត**

សំដៅទៅលើចិត្តរបស់ជនប្រព្រិត្តបទល្មើស ដែលបង្ករឡើងដោយចេតនា ឬអចេតនា បណ្តាលឱ្យមានបច្ចយ័កើតឡើង ហើយជននោះបានយល់ដឹងជាមុនថាអំពើរបស់ខ្លួនជាបទល្មើស ប៉ុន្តែព្យាយាមឱ្យមានលទ្ធផលកើតមានឡើង (មាត្រា ៤ ក្រមព្រហ្មទណ្ឌ)។

# ជំពូកទី១
# បទឧក្រិដ្ឋប្រល័យពូជសាសន៍
# បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និង បទឧក្រិដ្ឋសង្គ្រាម

## ១.បទឧក្រិដ្ឋប្រល័យពូជសាសន៍

### ១.១.និយមន័យ

-ផ្អែកតាមមាត្រា ១៨៣ ព្រហ្មទណ្ឌឆ្នាំ២០០៩ បានឱ្យនិយមន័យថាៈបទឧក្រិដ្ឋប្រល័យពូជសាសន៍ គឺជាអំពើណាមួយ ក្នុងចំណោមអំពើដែលរៀបរាប់ខាងក្រោមនេះ កាលបើអំពើនេះត្រូវបានប្រព្រឹត្តក្នុងគោលបំណងបំផ្លាញ ទាំងមូល ឬមួយផ្នែកនៃក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា ៖

១-លើសមាជិកនៃក្រុម ។

២-ការប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើបូរណភាពខាងរូបកាយ ឬសតិបញ្ញារបស់ សមាជិកនៃក្រុម ។

៣-ការដាក់ឱ្យសមាជិកនៃក្រុមរស់នៅក្នុងលក្ខខណ្ឌ ដែលនាំឱ្យវិនាសអន្តរាយ ទាំងស្រុង ឬមួយផ្នែកនៃក្រុម ។

៤-វិធានការដោយបង្ខំ ឬមធ្យោបាយដោយមិនបង្ខំ សំដៅរាំងកំណើតទារក នៅក្នុងក្រុម ។

៥-ជម្លៀសដោយបង្ខំនូវកុមារពីក្រុមមួយទៅក្រុមមួយផ្សេងទៀត ។

-ផ្អែកតាមមាត្រា៦នៃលក្ខន្តិកៈទីក្រុងរ៉ូម ថ្ងៃទី ១៧ខែ កក្កដា ឆ្នាំ១៩៩៨ បានចែងថា អំពើណាមួយដូចខាងក្រោមនេះដែលបានប្រព្រឹត្តឡើងដោយចេតនា បំផ្លិចបំផ្លាញទោះទាំងមូលក្តី ឬ ផ្នែកខ្លះក្តីនូវក្រុមជាតិសាសន៏ ក្រុមជាតិពន្ធុ ក្រុមពូជសាសន៏ ឬក្រុមសាសនាជាអាទិ៍ៈ

១-អំពើប្រល័យពូជសាសន៏ដោយការសម្លាប់

២-អំពើប្រល័យពូជសាសន៏ដោយការធ្វើឱ្យរបួសយ៉ាងធ្ងន់ធ្ងរ ដល់រូបរាងកាយប ឬសតិបញ្ញា

៣-អំពើប្រល័យពូជសាសន៏ដោយការធ្វើដោយចេតនា ឱ្យក្រុមណាមួយទទួលរងនូវស្ថានភាពរស់នៅមួយដែលបានរៀបចំឡើងសំរាប់បំផ្លិចបំផ្លាញ រាងកាយទាំងស្រុងឬមួយផ្នែក។

៤-អំពើប្រល័យពូជសាសន៏ ដោយការដាក់វិធានការនានា ដែលមានគោលបំណង រារាំងមិនឱ្យមានការផ្តល់កំណើតដល់ទារក។

៥-អំពើប្រល័យពូជសាសន៏ដោយការបញ្ជូនកុមារដោយបង្ខំ ។

### ១.២.ធាតុផ្សំបទល្មើស

#### ក.ធាតុនីត្យានុកូល

មាត្រា ១៨៤ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩បានកំណត់ បទឧក្រិដ្ឋប្រល័យពូជសាសន៍ត្រូវផ្តន្ទាទោសដាក់ ពន្ធនាគារអស់មួយជីវិត និងអាចត្រូវប្រកាសទោសបន្ថែម មួយចំនួន ក្នុងមាត្រា ១៨៦ ។

#### ខ.ធាតុសត្យានុម័ត

រាល់អំពើទាំងឡាយណាដែលបានប្រព្រឹត្តទៅលើ ក្រុមជាតិ ពូជសាសន៍ ឬសាសនា ណាមួយ

ជាក់លាក់ ក្នុងគោលបំណងបំផ្លាញចោលទាំងស្រុង ឬ ផ្នែកខ្លះ តាមរយៈ ការសំលាប់ ការរំលោភលើ បូរណភាពខាងរូបកាយ សតិបញ្ញាការដាក់ វិធានការដោយបង្ខំ ឬមធ្យោបាយនានា ដែលនាំឱ្យវិនាស អន្តរាយ ទាំងស្រុង ឬមួយផ្នែកនៃក្រុមជាតិសាសន៏ទាំងនោះ ចាត់ទុកជា បទឧក្រិដ្ឋប្រល័យពូជសាសន៍។

**គ.ធាតុអត្តនោម័ត**

ជនប្រព្រឹត្តមាន ចេតនាពិតប្រាកដ មានគោលដៅបំផ្លាញចោលឱ្យអស់ឬផ្នែកខ្លះ នៃក្រុមណា ណាមួយ ជាតិសាសន៍ឬសាសនា ណាមួយ។

## ២.បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ

### ២.១.និយមន័យ

- ផ្អែកតាមមាត្រា ១៨៨ ក្រមព្រហ្មទណ្ឌ បានឱ្យនិយមន័យថាៈ

បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ គឺជាអំពើណាមួយក្នុងចំណោមអំពើដែលរៀបរាប់ ខាងក្រោមនេះ កាលបើអំពើនេះត្រូវបានប្រព្រឹត្តនៅក្នុងក្របខ័ណ្ឌនៃការវាយលុកជាទូទៅឬ ជាប្រព័ន្ធ សំដៅប្រឆាំងប្រជា ជនស៊ីវិល ៖

១-ឃាតកម្ម ។

២-ការសម្លាប់រង្គាល ។

៣-ការធ្វើឱ្យទៅជាទាសករ ។

៤-ការនិរទេស ឬជម្លៀសប្រជាជនដោយបង្ខំ ។

៥-ការដាក់ពន្ធនាគារឬគ្រប់រូបភាពដទៃទៀតនៃការដកហូតយ៉ាងធ្ងន់ធ្ងរនូវ សេរីភាពដោយបំពាន ទៅលើបទប្បញ្ញត្តិគ្រឹះនៃនីតិអន្តរជាតិ ។

៦-ការធ្វើទារុណកម្ម ។

៧-ការចាប់បង្ខំសេពសន្ថវៈ ការធ្វើទាសកម្មខាងផ្លូវភេទ ពេស្យាចារដោយបង្ខំ ការមានគភ៌ដោយ បង្ខំ វិញ្ញកម្មដោយបង្ខំ និងគ្រប់រូបភាពផ្សេងទៀតនៃអំពើហិង្សា ខាងផ្លូវភេទ ដែលមានទម្ងន់ប្រហាក់ ប្រហែលគ្នា ។

៨-ការធ្វើទុក្ខបុកម្នេញលើក្រុម ឬសមូហភាពដោយមូលហេតុនយោបាយ ពូជសាសន៍ ក្រុមជាតិ ជាតិព ន្ធុ វប្បធម៌ សាសនា ឬភេទ ។

៩-ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ។

១០-ការអនុវត្តនយោបាយប្រកាន់ពូជសាសន៍ជាប្រព័ន្ធតាមបែបអាប៉ាថេដ ។

១១-គ្រប់អំពើអមនុស្សធម៌ផ្សេងទៀត ដែលបង្កឱ្យមានការឈឺចាប់យ៉ាងខ្លាំង ឬការប៉ះពាល់ យ៉ាងធ្ងន់ធ្ងរទៅលើ បូរណភាពខាងរូបកាយ ។

-ផ្អែកតាមមាត្រា ៧ នៃលក្ខន្តិកៈទីក្រុងរ៉ូមថ្ងៃទី១៧ ខែ កក្កដា ឆ្នាំ១៩៩៨ បានចែងថាៈ

អំពើណាមួយដូចខាងក្រោមនេះ ដែលបានប្រព្រិត្តឡើង ជាផ្នែកមួយនៃការវាយប្រហារដ៏សុះ

សាយ ឬដែលមានលក្ខណៈជាប្រពន្ធ័មួយដោយផ្ទាល់ប្រឆាំងទៅនឹង ប្រជាពលរដ្ឋស៊ីវិលណាម្នាក់ដោយមានការដឹងពីការវាយប្រហារនោះ៖

១-ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយការធ្វើមនុស្សឃាត

២-ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយការសំលាប់បំផុតពូជ

៣-ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយការធ្វើឱ្យទៅជាទាសករ

៤-ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដោយការនិរទេស ឬដោយការជម្លៀសប្រជាពលរដ្ឋដោយបង្ខំ

៥-ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយការ ដាក់ក្នុងមន្ទីឃុំឃាំង ឬការដកហូតយ៉ាងធ្ងន់ធ្ងរនូវ សេរីភាព រូបរាងកាយ។

៦-ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយ ការធ្វើទារុណកម្ម ។

៧-ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយការរំលោភផ្លូវភេទ ។

៨-ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយការធ្វើទាសករផ្លូវភេទ។

៩-ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយការធ្វើពេស្យាចារដោយបង្ខំ។

១០-ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយការធ្វើឱ្យមានគភ៌ដោយបង្ខំ។

១១-ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយការមិនឱ្យមានកូនដោយបង្ខំ។

១២-ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយអំពើហិង្សាផ្លូវភេទ។

១៣-ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយការធ្វើទុក្ខបុកម្នេញ ។

១៤-ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ។

១៥-ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយការរើសអើងពូជសាសន៍។

១៦-ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយអំពើអមនុស្សធម៌ផ្សេងៗទៀត។

### ២.២.ធាតុផ្សំបទល្មើស

#### ក.ធាតុនីត្យានុកូល

មាត្រា ១៨៩ ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ បានកំណត់ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ត្រូវផ្តន្ទាទោសដាក់ ពន្ធនាគារអស់មួយជីវិត និងអាចត្រូវប្រកាសទោសបន្ថែម មួយចំនួន ក្នុងមាត្រា ១៩១។

#### ខ.ធាតុសត្យានុម័ត

រាល់អំពើ ទាំងឡាយណាដែលបានប្រព្រិត្តដោយមាន ការចាត់តាំងឬជាប្រពន្ធ័ ដើម្បីប្រឆាំងទៅនឹងជនស៊ីវិលតាមគ្រប់រូបភាព ដូចជា៖ ឃាតកម្ម សម្លាប់រង្គាល ឱ្យធ្វើជាទាសករ ការនិរទេស ឬជម្លៀសដោយបង្ខំ ការការដកហូតសេរីភាពយ៉ាងធ្ងន់ធ្ងរ ការធ្វើទារុណកម្ម ការឈ្លានពានខាងផ្លូវភេទ ការធ្វើទុក្ខបុកម្នេញលើក្រុម ឬសមូហភាពដោយមូលហេតុនយោបាយ ពូជសាសន៍ ក្រុមជាតិ ជាតិពន្ធុ វប្បធម៌ សាសនា ឬភេទ ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ការអនុវត្តនយោបាយប្រកាន់ពូជសាសន៍ និងគ្រប់អំពើអមនុស្សធម៌ផ្សេងទៀត។

**គ.ធាតុអត្តនោម័ត**

ជនល្មើសមានចេតនា និងបានវាយប្រហារចូលសហគមន៍ ឬតំបន់ណាមួយ ហើយប្រព្រឹត្ត អំពើខាងលើ ដោយមិនរើសមុខ ទៅលើមនុស្សទូទៅ ឬទៅលើជនស៊ីវិល។

## ៣.បទឧក្រិដ្ឋសង្គ្រាម

### ៣.១.និយមន័យ

ផ្អែកតាមមាត្រា ១៩៣ ក្រមព្រហ្មទណ្ឌ បានឱ្យនិយមន័យ បទឧក្រិដ្ឋសង្គ្រាម ថា:

បទឧក្រិដ្ឋសង្គ្រាម គឺជាអំពើណាមួយក្នុងចំណោមអំពើដែលរៀបរាប់ ខាងក្រោមនេះ កាលបើ អំពើ នោះត្រូវបានប្រព្រឹត្តប្រឆាំងនឹងបុគ្គល ឬទ្រព្យសម្បត្តិ ដែលការពារដោយ អនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៤៩ ៖

១-ឃាតកម្ម ។

២-ទារុណកម្ម ឬគ្រប់អំពើអមនុស្សធម៌ រួមបញ្ចូលទាំងការពិសោធ ជីវសាស្ត្រ ។

៣-អំពើបង្កដោយចេតនានូវការឈឺចាប់ ឬដែលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ បូរណភាពខាងរូប កាយ ឬសុខភាព ។

៤-ការបំផ្លាញ ឬការធ្វើឱ្យខូចខាតធ្ងន់ធ្ងរទៅលើទ្រព្យសម្បត្តិ ដោយគ្មាន ហេតុផលចាំបាច់ខាង យោធា និងក្នុងទ្រង់ទ្រាយធំដោយខុសច្បាប់ និងតាមទំនើង ចិត្ត ។

៥-អំពើបង្ខំឈ្លើយសឹក ឬជនស៊ីវិល ឱ្យបម្រើក្នុងកងកម្លាំងប្រដាប់អាវុធរបស់ សត្រូវ ។

៦-អំពើដកហូតសិទ្ធិរបស់ឈ្លើយសឹក ឬជនស៊ីវិល ក្នុងការទទួលការវិនិច្ឆ័យ ដោយត្រឹមត្រូវ និង ឥតលំអៀង ។

៧-ជម្លៀស ការបញ្ជូន ឬការឃុំឃាំងជនស៊ីវិលដោយខុសច្បាប់ ។

៨-ការចាប់ជនស៊ីវិលជាចំណាប់ខ្មាំង ។

- ផ្អែកតាមមាត្រា ១៩៤ ក្រមព្រហ្មទណ្ឌ បានបន្ថែមទៀតថា:

អំពើណាមួយដូចមានចែងខាងក្រោមនេះ គឺ ជាបទឧក្រិដ្ឋសង្គ្រាមដែរ កាលបើ អំពើនោះ ត្រូវ បានប្រព្រឹត្តក្នុងឱកាសជម្លោះប្រដាប់អាវុធជាលក្ខណៈអន្តរជាតិ ឬមិន មែនអន្តរជាតិ ៖

១-ការប្រើប្រាស់អាវុធដែលមានជាតិពុល ឬអាវុធដែលស្ថាបនាឡើងដើម្បី បង្កការឈឺចាប់ឥត ប្រយោជន៍ ។

២-អំពើវាយប្រហារ ឬទម្លាក់គ្រាប់បែកដោយចេតនា តាមមធ្យោបាយណាក៏ដោយទៅលើទីក្រុង ភូមិ ទីកន្លែងរស់នៅ ឬអគារដែលមិនមានការការពារ និងដែល មិនមែនជាកម្មវត្ថុខាងយោធា ។

៣-អំពើវាយប្រហារដោយចេតនាទៅលើមនុស្ស ឬសម្ភារៈដែលប្រើប្រាស់ ក្នុងក្របខ័ណ្ឌនៃ បេសកកម្មមនុស្សធម៌ ដោយអនុលោមតាមធម្មនុញ្ញរបស់អង្គការ សហប្រជាជាតិ ។

៤-អំពើបង្កគ្រោះទុរ្ភិក្សដោយចេតនា ដល់ប្រជាជនស៊ីវិល ដោយដកហូតនូវ ទ្រព្យសម្បត្តិ

ចាំបាច់សម្រាប់បន្តការរស់រានមានជីវិតរបស់ជនស៊ីវិលទាំងនេះ ។

៥-អំពើប្រើប្រាស់ជនស៊ីវិល ដើម្បីបញ្ចៀសពីគោលដៅនៃប្រតិបត្តិការយោធា ទៅលើអគារខ្លះ តំបន់ខ្លះនៃដែនដី ឬកងកម្លាំងយោធាខ្លះ ។

៦-អំពើបំផ្លាញ ឬធ្វើឱ្យខូចខាតដោយចេតនា នូវអគារសម្រាប់សាសនា សប្បុរសធម៌ អប់រំ សិល្បៈ និងវិទ្យាសាស្ត្រ វិមានប្រវត្តិសាស្ត្រ ស្នាដៃសិល្បៈ ឬស្នាដៃ ដែលមានលក្ខណៈវិទ្យាសាស្ត្រ ។

៧-អំពើបង្កដល់បរិស្ថានធម្មជាតិ នូវការខូចខាតដ៏ធំ យូរអង្វែង និងធ្ងន់ធ្ងរ ដែលមានលក្ខណៈហួសហេតុយ៉ាងជាក់ ស្តែង បើប្រៀបទៅនឹងផលប្រយោជន៍ពិត ប្រាកដ និងផ្ទាល់ខាងផ្នែកយោធាដែលសង្ឃឹមទុក ។

៨-ការលួចប្លន់សម្បត្តិសាធារណៈ ឬឯកជន ។

**៣.២.ធាតុផ្សំបទល្មើស**

**ក.ធាតុនីត្យានុកូល**

មាត្រា ១៩៥ ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ បានកំណត់ បទឧក្រិដ្ឋសង្គ្រាម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយ ជីវិត និងអាចត្រូវប្រកាសទោសបន្ថែម មួយចំនួន ក្នុងមាត្រា ១៩៧ ។

**ខ.ធាតុសត្យានុម័ត**

អំពើទាំងឡាយណាដែលបានប្រឆាំងទៅនឹងមនុស្ស ឬទ្រព្យសម្បត្តិ តាមរយៈ ការប្រើប្រាស់អាវុធហាមឃាត់ ឬការប្រព្រឹត្តតាមទំនើងចិត្ត ប្រឆាំងទៅនឹងជនស៊ីវិល គោលដៅមនុស្ស អ្នករបួសឈ្លើយសឹក អ្នកមានជំងឺ ឬអ្នកកំពុង លិចកប៉ាល់.........។

**គ.ធាតុអត្តនោម័ត**

ជនល្មើសមានចេតនា ក្នុងការប្រើប្រាស់ និងប្រព្រឹត្តទៅលើជនរងគ្រោះ ឬទ្រព្យសម្បត្តិដែលបានការពារដោយច្បាប់អន្តរជាតិ។

# ជំពូកទី២
# ការប៉ះពាល់ដល់ជីវិតមនុស្ស

## ផ្នែកទី១.ការប៉ះពាល់ដោយចេតនាដល់ជីវិតមនុស្ស

ការប៉ះពាល់ដោយចេតនាដល់ជីវិតមនុស្ស ជាអំពើប្រព្រឹត្តដោយចេតនា របស់ជនណាម្នាក់ បានប្រើប្រាស់មធ្យោបាយផ្សេងៗ ដើម្បីសម្រេចបំណង ក្នុងការដកហូតជីវិតរបស់មនុស្ស ។ ផ្អែកតាមក្រមព្រហ្មទណ្ឌ នៅក្នុងផ្នែកទី១ នេះយើងសិក្សាទៅលើបទល្មើសចំនួន ៧ គឺ:

### ១.បទឃាតកម្ម

#### ១.១.និយមន័យ

តាមមាត្រា១៩៩ ក្រមព្រហ្មទណ្ឌចែងថា:អំពើសម្លាប់មនុស្សដោយចេតនា ដោយប្រើអាវុធ ឬមិនប្រើអាវុធដោយគ្មាន ស្ថានទម្ងន់ណាមួយដូចបានកំណត់ក្នុងមាត្រា ២០០(បទឃាតកម្មគិតទុកជាមុន) ដល់មាត្រា ២០៥ (បទឃាតកម្មដោយមានទារុណកម្ម អំពើឃោរឃៅ ឬអំពើ រំលោភសេពសន្ថវៈ) នៃក្រមនេះ គឺជាឃាតកម្ម ។ មានន័យថា បទឃាតកម្ម ជាអំពើសម្លាប់មនុស្សដោយចេតនាភ្លាមៗ គ្មានការគិតទុកជាមុន។

ឧទាហរណ៍:ពេលផឹកស៊ីទាស់សំដីគ្នា សុខ និង សៅ ក៏រើសយកឧបករណ៍នៅក្បែរខ្លួន វាយតប់គ្នា បណ្ដាលម្នាក់ស្លាប់។

#### ១.២.ធាតុផ្សំបទល្មើស

##### ក.ធាតុនីត្យានុកូល

តាមមាត្រា១៩៩ ក្រមព្រហ្មទណ្ឌបានកំណត់ថា បទឃាតកម្មត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ១៥ (ដប់ប្រាំ) ឆ្នាំ ។ ហើយបទល្មើសនេះ អាចត្រូវបានប្រកាសទោសបន្ថែមមួយចំនួន ក្នុងមាត្រា ២០៦ ទៀតផង។

##### ខ.ធាតុសត្យានុម័ត

ជាអំពើសកម្មទាំងឡាយណា របស់ចារី ដែលអាចផ្ដល់សេចក្ដីស្លាប់ដល់មនុស្ស ទោះបីមានការឈឺចាប់ ឬគ្មានឈឺចាប់ ទោះបីបង្កឱ្យជនរងគ្រោះស្លាប់ភ្លាម ឬមិនស្លាប់ភ្លាមក៏ដោយ ។ មានន័យថា រាល់អំពើប្រព្រឹត្តដោយចេតនាភ្លាមៗ ដែលអាចបណ្ដាលឱ្យមនុស្សស្លាប់ (មនុស្សមានជីវិតរស់ ទោះបីជាមនុស្សនោះស្ថិតក្នុងលក្ខណៈ ឬស្ថានភាពអ្វីក៏ដោយ) ឱ្យតែអំពើនោះចេញជារូបរាងពិតប្រាកដ ហើយមាន

ទំនាក់ទំនងហេតុផលបង្កឱ្យមនុស្សស្លាប់ ជាបទឃាតកម្ម ដែលត្រូវផ្តន្ទាទោស។

ឧទាហរណ៍ ខាងលើប្រសិនបើ សុខ វាយសៅបណ្តាលឱ្យមានរបួស បន្ទាប់មក សៅ ត្រូវក្រុមគ្រួសារដឹកទៅព្យាបាលហើយបានគ្រោះថ្នាក់ចរាចរ តាមផ្លូវ បណ្តាលឱ្យ សៅ ត្រូវឡានកិនស្លាប់។ការស្លាប់របស់ សៅ បណ្តាលមកពីគ្រោះថ្នាក់ចរាចរ រីឯសុខទទួលខុសត្រូវព្រហ្មទណ្ឌ ត្រឹមការធ្វើឱ្យសៅមានរបួស។

**គ.ធាតុអត្តនោម័ត**

ជនប្រព្រឹត្តមានចេតនាពិតប្រាកដ ក្នុងការបង្ករព្យសនកម្ម គោលបំណងដកហូតជីវិតរបស់ជនរងគ្រោះភ្លាមៗ ដោយគ្មានការគ្រោង រៀបចំគិតទុកជាមុន ។

## ២.បទឃាតកម្មគិតទុកជាមុន

### ២.១.និយមន័យ

តាមមាត្រា ២០០ ក្រមព្រហ្មទណ្ឌចែងថា:ឃាតកម្មគិតទុកជាមុន គឺអំពើសម្លាប់មនុស្សដោយគិតទុកជាមុន ឬដោយការ ពួនស្ទាក់ ។

ការគិតទុកជាមុន គឺជាគម្រោងដែលបង្កើតឡើងមុនអំពើហិង្សាទៅលើ រូបបុគ្គលនៃជនរងគ្រោះ ។ ការពួនស្ទាក់ គឺជាអំពើឃ្លាំចាំបុគ្គលណាម្នាក់ ក្នុងរយៈពេលមួយរយៈ ដើម្បី ប្រព្រឹត្តអំពើហិង្សាទៅលើរូបបុគ្គល នៃជនរងគ្រោះ ។

### ២.២.ធាតុផ្សំបទល្មើស

**ក.ធាតុនីត្យានុកូល**

តាមមាត្រា ២០០ ក្រមព្រហ្មទណ្ឌបានកំណត់ថាឃាតកម្មគិតទុកជាមុន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត។បទល្មើសនេះអាចត្រូវបានប្រកាសទោសបន្ថែមមួយចំនួនក្នុងមាត្រា ២០៦ទៀតផង។

**ខ.ធាតុសត្យានុម័ត**

រាល់អំពើសកម្មទាំងឡាយណា ដែលអាចផ្តល់សេចក្តីស្លាប់ដល់មនុស្ស ដោយជនប្រព្រឹត្តបានប្រើប្រាស់មធ្យោបាយ ត្រៀមរៀបចំឧបករណ៍ផ្សេងៗ ឬការពួនស្ទាក់ទោះក្នុងរយៈពេល យូរ ឬឆាប់ក៏ដោយ គោលបំណងធ្វើឱ្យគ្រោះថ្នាក់ដល់ជីវិតជនរងគ្រោះ។

ឧទាហរណ៍: ដោយមានគំនុំវាយតប់គ្នាគន្លងមក សុខ បានទិញកូនកាំបិតមុតស្រួចមួយ ដាក់តាមខ្លួនទៅចាក់សម្លាប់ សៅ នៅពេល សៅ ចេញពីវាំ(សុខ ទិញកាំបិតដាក់តាមខ្លួនគោលបំណងប្រើប្រាស់ជាអាវុធសម្លាប់ សៅ ជាការត្រៀមរៀបចំ រីឯការពួនស្ទាក់ ត្រង់ សុខចាំវាយប្រហារទៅ សៅ ពេលចេញពីវាំ)។

**គ.ធាតុអត្តនោម័ត**

ជនប្រព្រឹត្តមានចេតនាពិតប្រាកដ ក្នុងការបង្ករព្យសនកម្ម គោលបំណងដកហូតជីវិតរបស់ជនរងគ្រោះ។

## ៣.បទឃាតកម្មដោយការប្រើថ្នាំពុល

### ៣.១.និយមន័យ

បទឃាតកម្មដោយការប្រើថ្នាំពុល ជាអំពើសម្លាប់មនុស្សដោយចេតនា ដោយយកថ្នាំពុល ធ្វើជាមធ្យោបាយក្នុងការសម្លាប់ ទោះបីជាប្រភេទថ្នាំពុលអ្វីក៏ដោយ ឱ្យតែអាចធ្វើឱ្យស្លាប់មនុស្ស ។

### ៣.២.ធាតុផ្សំបទល្មើស

**ក.ធាតុនីត្យានុកូល**

តាមមាត្រា ២០១ ក្រមព្រហ្មទណ្ឌបានកំណត់ថា ឃាតកម្មដែលប្រព្រឹត្តដោយ ការប្រើថ្នាំពុល ត្រូវផ្តន្ទាទោស ដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ)ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ។ បទល្មើសនេះ អាចត្រូវបានប្រកាសទោសបន្ថែមមួយចំនួន ក្នុងមាត្រា ២០៦ ទៀតផង។

**ខ.ធាតុសត្យានុម័ត**

រាល់អំពើសកម្មទាំងឡាយណា ដែលអាចផ្តល់សេចក្តីស្លាប់ដល់មនុស្ស ដោយជនប្រព្រឹត្តបានយកថ្នាំពុល ប្រើប្រាស់ជាមធ្យោបាយក្នុងការធ្វើឱ្យគ្រោះថ្នាក់ ដល់ជីវិតជនរងគ្រោះ ។ ជាទូទៅជនប្រព្រឹត្តបានត្រៀមរៀបចំទុកជាមុន។

**គ.ធាតុអត្តនោម័ត**

ជនប្រព្រឹត្តមានចេតនាពិតប្រាកដ ក្នុងការបង្ករព្យសនកម្ម គោលបំណងដកហូតជីវិតជនរងគ្រោះដោយប្រើថ្នាំពុល។

## ៤.បទឃាតកម្មដែលមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ

### ៤.១.និយមន័យ

តាមមាត្រា២០២ ក្រមព្រហ្មទណ្ឌចែងថា: អំពើដកហូតជីវិតមនុស្ស កាលបើអំពើនេះត្រូវបានប្រព្រឹត្តទៅលើ ៖

១-បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុអាយុនៃបុគ្គលនោះ ។

២-នារីមានគភ៌ កាលបើគភ៌ត្រូវបានគេឃើញជាក់ស្តែង ឬកាលបើជនល្មើស បានដឹង ។

៣-បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុនៃជំងឺ ឬពិការភាព កាលបើស្ថានភាពបុគ្គលនេះ ត្រូវបានគេឃើញជាក់ស្តែង ឬកាលបើជនល្មើសបានដឹង ។

៤-អ្នករាជការសាធារណៈ នៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬនៅក្នុងឱកាសនៃការ បំពេញមុខងាររបស់ខ្លួន ។

## ៤.២.ធាតុផ្សំបទល្មើស

### ក.ធាតុនីត្យានុកូល

តាមមាត្រា២០២ ក្រមព្រហ្មទណ្ឌបានកំណត់ថា បទឃាតកម្មដែលមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំទៅ ៣០ (សាមសិប) ឆ្នាំ។បទល្មើសនេះអាចត្រូវបានប្រកាសទោសបន្ថែមមួយចំនួន ក្នុងមាត្រា ២០៦ ទៀតផង ។

### ខ.ធាតុសត្យានុម័ត

-រាល់អំពើសម្លាប់មនុស្សដោយចេតនា ដែលបានប្រព្រឹត្តទៅលើ អ្នករាជការ

-ឬជនទាំងឡាយដែលបានប្រព្រឹត្តទៅលើជនរងគ្រោះ ទន់ខ្សោយ ដោយខ្លួនឃើញជាក់ស្តែង ឬបានដឹង ហើយនៅតែប្រព្រឹត្ត ទៅលើ បុគ្គលទាំងនោះ ដូចជា ជនរងគ្រោះអាយុតិច ស្ត្រីមានគភ៌ អ្នកមានជម្ងឺ ឬពិការភាព ។

### គ.ធាតុអត្តនោម័ត

ជនប្រព្រឹត្តមានចេតនាពិតប្រាកដ ក្នុងការបង្ករព្យសនកម្ម គោលបំណងដកហូតជីវិតរបស់ជនរងគ្រោះ។

# ៥.បទឃាតកម្មដែលមានស្ថានទម្ងន់ទោសដោយសារគោលដៅ

## ៥.១.និយមន័យ

តាមមាត្រា២០៣ ក្រមព្រហ្មទណ្ឌចែងថាៈ កាលបើអំពើនេះត្រូវបានប្រព្រឹត្តទៅលើ ៖

១-ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីរារាំងជននេះកុំឱ្យប្តឹងបរិហារ ពីបទល្មើស ឬសុំឱ្យធ្វើការជួសជុលព្យសនកម្ម ។

២-សាក្សីដើម្បីរារាំងកុំឱ្យឆ្លើយផ្តល់ភស្តុតាងនៅពេលស៊ើបអង្កេត ស៊ើបសួរ សវនាការ ឬនៅក្នុងនីតិវិធីនៃបណ្តឹងផ្សេងទៀត ។

៣-ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី ពីព្រោះជននេះបានបរិហារពី បទល្មើស ឬសុំឱ្យជួស

ផុលព្យសនកម្ម ។

៩-សាក្សី ដោយមូលហេតុសាក្សីនេះបានផ្តល់ ភស្តុតាងនៅពេលស៊ើបអង្កេត ស៊ើបសួរ សវនាការ ឬនៅក្នុងនីតិវិធី នៃបណ្តឹងផ្សេងទៀត ។

**៥.២.ធាតុផ្សំបទល្មើស**

**ក.ធាតុនីត្យានុកូល**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ។ បទល្មើសនេះអាចត្រូវបាន ប្រកាសទោសបន្ថែមមួយចំនួន ក្នុងមាត្រា ២០៦ ទៀតផង។

**ខ.ធាតុសត្យានុម័ត**

រាល់អំពើប្រព្រឹត្តដោយមានការគិតទុកជាមុន ដើម្បីដកហូតជីវិត ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីក្នុងគោលដៅលាក់បាំងអត្ថិភាពនៃបទល្មើស ឬរារាំងកុំឱ្យ ជនទាំងនោះប្តឹងបរិហារឬប្តឹងទាមទារសំណង។

ឧទាហរណ៍:ដោយខឹងសាក្សី ឆ្លើយបំភ្លឺការពិតជូនតុលាការ ជនប្រព្រឹត្តបានធ្វើឃាតទៅលើសាក្សី។

**គ.ធាតុអត្តនោម័ត**

ជនប្រព្រឹត្តមានចេតនា និងគោលដៅច្បាស់លាស់ ក្នុងការដកហូតជីវិតរបស់ជនរងគ្រោះ ។

**៦.បទឃាតកម្មប្រព្រឹត្តដោយអ្នករាជការសាធារណៈ**

**៦.១.និយមន័យ**

បទឃាតកម្មប្រព្រឹត្តដោយអ្នករាជការសាធារណៈជាអំពើប្រព្រឹត្តដែលធ្វើឡើងដោយអ្នករាជការសាធារណៈនៅក្នុង ក្របខ័ណ្ឌនៃមុខងារ ឬនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន ហើយបានបង្កគ្រោះថ្នាក់ដល់ជីវិត នៃជនដទៃដោយចេតនា។

**៦.២.ធាតុផ្សំបទល្មើស**

**ក.ធាតុនីត្យានុកូល**

តាមមាត្រា២០៤ ក្រមព្រហ្មទណ្ឌបានកំណត់ថា បទឃាតកម្មប្រព្រឹត្តដោយអ្នករាជការសាធារណៈត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ និងអាចត្រូវបាន ប្រកាសទោសបន្ថែមមួយ ចំនួន ក្នុងមាត្រា ២០៦ ។

**ខ.ធាតុសត្យានុម័ត**

រាល់អំពើឃាតកម្មដោយចេតនា ដែល ប្រព្រិត្តដោយអ្នករាជការ សាធារណៈ នៅក្នុង ក្របខ័ណ្ឌនៃមុខងារ ឬនៅក្នុងឱកាស នៃការបំពេញមុខងាររបស់ខ្លួនចាត់ទុកជា បទឃាតកម្មដែលមានស្ថានទម្ងន់ទោសដូចខាងលើ។

ឧទាហរណ៏:មន្ត្រីនគរបាលយុត្តិធម៏ខឹងដេញចាប់ចោរហាត់ពេក ពេលចាប់បានក៏សម្លាប់ចោរនោះ។

**គ.ធាតុអត្តនោម័ត**

ជនប្រព្រិត្តជាមន្ត្រីរាជការសាធារណៈ បាន ដកហូតជីវិតរបស់ជនរងគ្រោះ ដោយចេតនា។

## ៧-បទឃាតកម្មដោយមានទារុណកម្ម អំពើឃោរឃៅ ឬអំពើរំលោភសេពសន្ថវៈ

### ៧.១-និយមន័យ

មាត្រា ២០៥ ក្រមព្រហ្មទណ្ឌបានចែងថាៈ ឃាតកម្មដែលកើតក្នុងពេល ឬ ក្រោយពេលប្រព្រឹត្តអំពើទារុណកម្មអំពើ ឃោរឃៅ ឬអំពើរំលោភសេពសន្ថវៈ ។

### ៧.២-ធាតុផ្សំបទល្មើស

**ក-ធាតុនីត្យានុកូល**

ផ្អែកតាមមាត្រា ២០៥ ក្រមព្រហ្មទណ្ឌ បទឃាតកម្មដោយមានទារុណកម្ម អំពើឃោរឃៅ ឬអំពើរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត និង អាចត្រូវបាន ប្រកាសទោសបន្ថែមមួយចំនួន ក្នុងមាត្រា ២០៦។

**ខ-ធាតុសត្យានុម័ត**

រាល់អំពើដែលបាន រំលោភសេពសន្ថវៈ ការធ្វើទារុណកម្ម ឬអំពើឃោរឃៅ ទៅលើជនរងគ្រោះ ក្នុងពេលឬក្រោយពេល សំលាប់ជនរងគ្រោះ ។ មានន័យថាមានអំពើមួយទៀតកើតឡើង ក្នុងពេលប្រព្រិត្តបទឃាតកម្មនោះ។

ឧទាហរណ៏:រំលោភជនរងគ្រោះរួច សម្លាប់ជនរងគ្រោះជាក្រោយ។

**គ-ធាតុអត្តនោម័ត**

ជនប្រព្រិត្តមានចេតនាធ្វើឱ្យជនរងគ្រោះមានឈឺចាប់ រួចសម្លាប់ជនរងគ្រោះ ។

## ៨.អំពីទោសបន្ថែម

មាត្រា ២០៦-ទោសបន្ថែម ៖ ប្រភេទ និងរយៈពេល

ចំពោះបទឧក្រិដ្ឋដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះអាចត្រូវ បានប្រកាស ៖

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទឧក្រិដ្ឋត្រូវបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈឬនៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន

៣-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ។

៤-ការហាមឃាត់ដល់ទណ្ឌិតបរទេសចំពោះការចូល ឬការស្នាក់នៅក្នុងដែនដី នៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុដទៃទៀត ដែលប្រើសម្រាប់ប្រព្រឹត្ត បទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៦-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

៧-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៨-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៩-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសតាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ផ្នែកទី២.បទមនុស្សឃាតដោយអចេតនា

### ១-និយមន័យ

មាត្រា ២០៧ ក្រមព្រហ្មទណ្ឌចែងថាៈបទមនុស្សឃាតដោយអចេតនា ជាអំពើបណ្តាលឱ្យស្លាប់អ្នកដទៃដោយៈ

១-ការធ្វេសប្រហែស ការមិនប្រុងប្រយ័ត្ន ឬការខ្ជីខ្ជា ។

២-ការបំពានលើកាតព្វកិច្ចសន្តិសុខ ឬកាតព្វកិច្ចប្រុងប្រយ័ត្នដែលច្បាប់តម្រូវ ។

### ២-ធាតុផ្សំបទល្មើស

#### ក-ធាតុនីត្យានុកូល

មាត្រា ២០៧ បទមនុស្សឃាតដោយអចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី)ឆ្នាំនិងពិន័យជាប្រាក់ពី២.០០០.០០០ (ពីរលាន)រៀល ទៅ ៦.០០០.០០០(ប្រាំមួយលាន) រៀលនិងអាចត្រូវបានប្រកាសទោសបន្ថែមដូចមានចែងក្នុង មាត្រា ២០៨។

#### ខ-ធាតុសត្យានុម័ត

រាល់អំពើ ធ្វេសប្រហែស ការមិនប្រុងប្រយ័ត្ន ឬការខ្ជីខ្ជា ការបំពានលើកាតព្វកិច្ចសន្តិសុខ ឬកាតព្វកិច្ចប្រុងប្រយ័ត្នដែលច្បាប់តម្រូវ ហើយបណ្តាលឱ្យមនុស្សស្លាប់ ចាត់ទុកជាបទល្មើសព្រហ្មទណ្ឌ គឺបទមនុស្សឃាតដោយអចេតនា។

-**ការធ្វេសប្រហែស:** ជាការភ្លេច ឬការខ្វិលច្រអូស បង្ករឱ្យជនរងគ្រោះបាត់បង់ជីវិត។

ឧទាហរណ៏:ពេទ្យវះកាត់អ្នកជំងឺ ដេររួចភ្លេចកាំបិតក្នុងពោះ

-**ការមិនប្រុងប្រយ័ត្ន ឬការខ្ជីខ្ជា:** ជាអំពើគ្មានការយកចិត្តទុកដាក់ បណ្តែតបណ្តោយឱ្យមានគ្រោះថ្នាក់ ដល់អាយុជីវិតអ្នកដទៃ។

ឧទាហរណ៏:អ្នកបើកបររថយន្ត ពេលចេញដំណើរ មិនបានត្រួតពិនិត្យទ្វារឡាន បណ្តាលឱ្យធ្លាក់អ្នកដំណើរស្លាប់។

-**ការបំពានលើកាតព្វកិច្ចសន្តិសុខ ឬកាតព្វកិច្ចប្រុង ប្រយ័ត្នដែលច្បាប់តម្រូវ:** ការមិនគោរពតាមបញ្ញត្តិច្បាប់ ឬបទ បញ្ជា ណាមួយ ហើយបង្ករឱ្យមានគ្រោះថ្នាក់ដល់ជីវិត។

ឧទាហរណ៏:អ្នកបើកបរឃើញផ្លាកសញ្ញា កំណត់ល្បឿនហើយ មិនគោរព បណ្តាលឱ្យគ្រោះថ្នាក់ដល់អាយុជីវិតអ្នកដទៃ។

**គ-ធាតុអត្តនោម័ត**

ជនប្រព្រឹត្ត គ្មានគោលបំណងធ្វើឱ្យ កើតមានគ្រោះថ្នាក់ដល់ជីវិតមនុស្សទេ ប៉ុន្តែអំពើរបស់ខ្លួន មានការធ្វេសប្រហែសការមិនប្រុងប្រយ័ត្ន ឬការខ្ជីខ្ជា ការបំពានលើកាតព្វកិច្ចសន្តិសុខ ឬ កាតព្វកិច្ចប្រុងប្រយ័ត្នដែលច្បាប់តម្រូវ ហើយបណ្តាលឱ្យមនុស្សស្លាប់ ដោយអចេតនា។

ជាទូទៅបើគ្មានចេតនាប្រព្រឹត្តគឺពុំមានទោសទេ ប៉ុន្តែការផ្តន្ទាទោស ដោយការប្រព្រឹត្តអចេតនាខាងលើនេះ កើតចេញពីគោលការណ៏ទូទៅដែលមានចែងក្នុងមាត្រា៤ នៃក្រមព្រហ្មទណ្ឌ ។

**៣.អំពីទោសបន្ថែម**

មាត្រា ២០៨-ទោសបន្ថែម ៖ ប្រភេទ និងរយៈពេល

ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាសចំពោះបទមនុស្សឃាតដោយ អចេតនា ៖

១-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្ត នៅក្នុងការប្រកបវិជ្ជាជីវៈ ឬនៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការបើកបរយានយន្ត ទោះបីជាប្រភេទណាក៏ដោយសម្រាប់រយៈពេល

៥ឆ្នាំយ៉ាងច្រើន

៣-ការព្យួរលិខិតបើកបរ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៤-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ សម្រាប់ រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៦-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៧-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយ ទូរគមនាគមន៍ សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

**៤.ការទទួលខុសត្រូវរបស់នីតបុគ្គល**

មាត្រា២០៩-ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែល មានចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមនេះ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ២០៧ បទមនុស្សឃាតដោយអចេតនា) នៃក្រមនេះ ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី១០.០០០.០០០(ដប់លាន)រៀលទៅ៥០.០០០.០០០ (ហាសិបលាន)រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើន ដូចតទៅនេះ ៖

១-ការរំលាយតាមបែបបទកំណត់ដោយមាត្រា១៧០(ការរំលាយនិងការជម្រះបញ្ជីនៃនីតិបុគ្គល) នៃក្រមនេះ។

២-ការដាក់ឱ្យស្ថិតនៅក្រោមការតាមដានត្រួតពិនិត្យរបស់តុលាការតាម បែបបទកំណត់ដោយមាត្រា១៧១ (ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យ តាមដានរបស់តុលាការ) នៃក្រមនេះ ។

៣-ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយ ឬច្រើន តាមបែបបទកំណត់ ដោយ មាត្រា ១៧២ (ការហាមឃាត់ ចំពោះការធ្វើសកម្មភាព) នៃក្រមនេះ ។

៤-ការបិទគ្រឹះស្ថានដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស តាមបែបបទ កំណត់ដោយ មាត្រា ១៧៦ (ការបិទគ្រឹះស្ថាន) នៃក្រមនេះ ។

៥-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន ដែលបើកចំហដល់ សាធារណជន ឬដែលប្រើប្រាស់ដោយសាធារណជនតាមបែបបទកំណត់ដោយមាត្រា ១៧៧ (ការហាមឃាត់ចំពោះការ

ធ្វើអាជីវកម្មលើគ្រឹះស្ថាន) នៃក្រមនេះ។

៦-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោសតាមបែបបទកំណត់ដោយមាត្រា១៨០(ការបិទផ្សាយសេចក្តីសម្រេច) នៃក្រមនេះ ។

៧-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស នៅក្នុងសារព័ត៌មានសរសេរ ឬ ការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយ មាត្រា ១៨១ (ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ ជាអាទិ៍) នៃក្រមនេះ ។

# ជំពូកទី៣
# ការប៉ះពាល់ដល់បូរណភាពនៃបុគ្គល

## ផ្នែកទី១.ទារុណកម្ម និង អំពើឃោរឃៅ

### ១.និយមន័យ

-តាមវចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត បានឱ្យនិយមន័យថា: ទារុណកម្ម ជាអំពើកាច អំពើអាក្រក់ អំពើសាហាវយង់ឃ្នង និងពាក្យ ឃោរឃៅ មានន័យថា:ខ្លាំងពេក កាចខ្លាំង ឥតមានមេត្តាប្រណី ។

-មាត្រា ១ អនុសញ្ញាប្រឆាំង ទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅអមនុស្សធម៌ឬ បន្ថោកបន្ទាប ដែលអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ ថ្ងៃទី ១០ខែ ធ្នូ ឆ្នាំ ១៩៨៤ ចូលជាធរមានថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៨៧ ហើយកម្ពុជាផ្តល់សច្ចាប័ន ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩២ ចែងថា:ទារុណកម្ម ជាអំពើទាំងឡាយណា ដែលនាំឱ្យមានការឈឺចាប់ ឬរងទុក្ខខ្លាំង ទោះផ្លូវកាយ ឬ ផ្លូវចិត្តក្តី ដែលត្រូវបានបង្កឡើងដោយចេតនា ទៅលើជនណាម្នាក់ ក្នុងគោលបំណងទាំងឡាយណាដូចជា ទាញយកពត៏មាន ពីជននោះ ឬតតិយជនណាម្នាក់។

ដូចនេះ បទទារុណកម្ម និង អំពើឃោរឃៅ ជាអំពើអាក្រក់ កាចសាហាវយង់ឃ្នង ឥតត្រាប្រណី ប្រព្រឹត្តតាមគ្រប់មធ្យោបាយ បែបអមនុស្សធម៌ បង្កឱ្យជនរងគ្រោះឈឺចាប់ ដើម្បីសួរយកចម្លើយ។

### ២.ធាតុផ្សំបទល្មើស

**២.១.ធាតុនីត្យានុកូល** តាមមាត្រា ២១០.ក្រមព្រហ្មទណ្ឌបានចែងថា:

ទារុណកម្ម ឬអំពើឃោរឃៅដែលប្រព្រឹត្តទៅលើបុគ្គលណាមួយ ត្រូវផ្តន្ទាទោស ដាក់ពន្ធនាគារ ពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ ( ដប់ប្រាំ) ឆ្នាំ ។

**២.២.ធាតុសត្យានុម័ត**

រាល់អំពើ ធ្វើទារុណកម្ម និងអំពើឃោរឃៅទៅលើមនុស្ស ដែលស្តែងឡើង តាមគ្រប់រូបភាពដើម្បីសម្រេចគោលបំណងអ្វីមួយ បង្កឱ្យជនរងគ្រោះឈឺចាប់ ចាត់ទុកជា បទទារុណកម្ម និងអំពើឃោរឃៅ។

**២.៣.ធាតុអត្តនោម័ត**

ជនប្រព្រឹត្តមានចេតនាទុច្ចរិត យល់ដឹងរូវអំពើរបស់ខ្លួន ហើយនៅតែបង្កព្យសនកម្មធ្ងន់ធ្ងរ ទៅលើជនរងគ្រោះ ។

### ៣.អំពីទោស

**៣.១.ទោសបទទារុណកម្មនិងអំពើឃោរឃៅ**

តាមមាត្រា ២១០ បទទារុណកម្មនិងអំពើឃោរឃៅ ត្រូវផ្តន្ទាទោស ដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ ( ដប់ប្រាំ) ឆ្នាំ ។

**៣.២.ស្ថានទម្ងន់ទោស**

**ក.ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ**

រាល់ការប្រព្រឹត្តបទទារុណកម្មនិងអំពើឃោរឃៅ ទៅលើជនរងគ្រោះ ជាបុគ្គលទន់ខ្សោយដោយសារ ៖ អាយុដោយសារជំងឺ-ឬ ពិការភាព ឬទៅលើ នារីមានគភ៌ ដោយមានចេតនាបានដឹង ឬបានឃើញជាមុន ត្រូវមានស្ថានទម្ងន់ទោសនឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ ឆ្នាំ ទៅ ២០ឆ្នាំ ។

មាត្រា ២១១.ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ

បទឧក្រិដ្ឋដែលមានចែងនៅក្នុងមាត្រា២១០(បទទារុណកម្មនិងអំពើ ឃោរឃៅ) នៃក្រមនេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ កាលបើអំពើនេះ ត្រូវបានប្រព្រឹត្តទៅលើៈ

១-បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុអាយុនៃបុគ្គលនោះ ។

២-នារីមានគភ៌ កាលបើគភ៌ត្រូវបានគេឃើញជាក់ស្តែង ឬកាលបើជនល្មើស បានដឹង ។

៣-បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុនៃជំងឺ ឬពិការភាព កាលបើស្ថានភាពបុគ្គលនេះត្រូវបានគេឃើញជាក់ស្តែង ឬកាលបើជនល្មើសបានដឹង ។

**ខ.ស្ថានទម្ងន់ទោសដោយសារគោលដៅ**

រាល់ការប្រព្រឹត្ត បទទារុណកម្ម និងអំពើឃោរឃៅ ទៅលើជនរងគ្រោះ ឬ ដើមបណ្តឹងរដ្ឋប្បវេណីឬ សាក្សី គោលបំណង ៖ រារាំងកុំឱ្យប្តឹងបរិហារពីបទល្មើស កុំឱ្យទាមទារសំណង កុំឱ្យផ្តល់ភស្តុតាង ឬខឹងនឹងជនរងគ្រោះប្តឹង សាក្សីបានផ្តល់ភស្តុតាង ត្រូវមានស្ថានទម្ងន់ទោស ដោយសារគោលដៅ។

មាត្រា ២១២.ស្ថានទម្ងន់ទោសដោយសារគោលដៅ

បទឧក្រិដ្ឋដែលមានចែងនៅក្នុងមាត្រា ២១០(បទទារុណកម្ម និងអំពើឃោរឃៅ)នៃក្រមនេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ កាលបើអំពើនេះ ត្រូវបានប្រព្រឹត្តទៅលើៈ

១-ជនរងគ្រោះឬដើមបណ្តឹងរដ្ឋប្បវេណីដើម្បីរារាំងជននេះកុំឱ្យប្តឹងបរិហារពីបទល្មើស ឬសុំឱ្យធ្វើការជួសជុលព្យសនកម្ម ។

២-សាក្សីដើម្បីរារាំងកុំឱ្យឆ្លើយផ្តល់ភស្តុតាងនៅពេលស៊ើបអង្កេតស៊ើបសួរសវនាការ ឬនៅក្នុងនីតិវិធីនៃបណ្តឹងផ្សេងទៀត ។

៣-ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី ពីព្រោះជននេះបានបរិហារពី បទល្មើស ឬសុំឱ្យជួសជុលព្យសនកម្ម ។

៤-សាក្សី ដោយមូលហេតុសាក្សីនេះបានផ្តល់ភស្តុតាងនៅពេលស៊ើបអង្កេត ស៊ើបសួរ សវនាការ ឬនៅក្នុងនីតិវិធីនៃបណ្តឹងផ្សេងទៀត ។

**គ.ស្ថានទម្ងន់ទោសទាក់ទងទៅនឹងចារី**

រាល់អំពើរបស់មន្ត្រីរាជការសាធារណៈ ដែលបានប្រព្រឹត្ត បទទារុណកម្ម និងអំពើឃោរឃៅ ទៅលើជនរងគ្រោះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ១០ ឆ្នាំ ទៅ ២០ ឆ្នាំ ។ មានន័យថា បើមន្ត្រីរាជការសធារណៈបានប្រព្រឹត្តបទទារុណកម្មនិងអំពើឃោរឃៅនៅក្នុងក្របខណ្ឌនៃមុខងារ ឬក្នុងឱកាសបំពេញ

ការងារ ត្រូវមានស្ថានទម្ងន់ទោស។

មាត្រា ២១៣.ស្ថានទម្ងន់ទោសទាក់ទងទៅនឹងចារី

បទឧក្រិដ្ឋដែលមានចែងនៅក្នុងមាត្រា២១០(បទទារុណកម្ម និងអំពើ ឃោរឃៅ) នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០(ដប់) ឆ្នាំ ទៅ ២០(ម្ភៃ) ឆ្នាំកាលបើបទឧក្រិដ្ឋនេះត្រូវបានប្រព្រឹត្តដោយអ្នករាជការសាធារណៈនៅក្នុង ក្របខ័ណ្ឌនៃមុខងារ ឬនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន ។

**ឃ.ស្ថានទម្ងន់ទោសដោយសារការកាត់អវយវៈ ឬពិការភាព**

ការប្រព្រឹត្ត បទទារុណកម្មនិងអំពើឃោរឃៅ បណ្តាលឱ្យជនរងគ្រោះ កាត់អវៈយវៈ ឬជនរងគ្រោះពិការភាពជាអចិន្ត្រៃយ៍ ត្រូវមានស្ថានទម្ងន់ទោស។

មាត្រា ២១៤.ស្ថានទម្ងន់ទោសដោយសារការកាត់អវយវៈ ឬពិការភាព

បទឧក្រិដ្ឋដែលមានចែងនៅក្នុងមាត្រា២១០(បទទារុណកម្ម និងអំពើ ឃោរឃៅ) នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ កាលបើបទឧក្រិដ្ឋនេះនាំឱ្យមានការកាត់អវយវៈ ឬឱ្យមានពិការភាព ជាអចិន្ត្រៃយ៍ ដល់ជនរងគ្រោះ ។

**ខ.ស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ**

មាត្រា ២១៥.- ស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ

បទឧក្រិដ្ឋដែលមានចែងនៅក្នុងមាត្រា២១០(បទទារុណកម្ម និងអំពើ ឃោរឃៅ) នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ កាលបើបទឧក្រិដ្ឋនេះ បណ្តាលឱ្យជនរងគ្រោះស្លាប់ ដោយគ្មាន ចេតនាសម្លាប់ ឬនាំឱ្យមានអត្តឃាតរបស់ជននោះ។

**៣.៣.ទោសបន្ថែម**

ក្រៅពីទោសដាក់ពន្ធនាគារខាងលើ បទទារុណកម្មនិងអំពើឃោរឃៅ អាចត្រូវបានប្រកាសទោសបន្ថែមមួយចំនួនទៀតដូចខាងក្រោមៈ

មាត្រា ២១៦.ទោសបន្ថែម ៖ ប្រភេទ និងរយៈពេល

ចំពោះបទឧក្រិដ្ឋដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះអាចត្រូវ បានប្រកាស ៖

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះ ការប្រកបវិជ្ជាជីវៈ កាលបើបទឧក្រិដ្ឋត្រូវបានប្រព្រឹត្ត នៅក្នុងការប្រកបវិជ្ជាជីវៈឬនៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ។

៤-ការហាមឃាត់ដល់ទណ្ឌិតបរទេសចំពោះការចូល ឬការស្នាក់នៅក្នុងដែនដី នៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុដទៃទៀត ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៦-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

៧-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៨-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៩-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

**ផ្នែកទី២.អំពើហិង្សាដោយចេតនា**

**១.និយមន័យ**

តាមវចនានុក្រមសម្តេច ជួន ណាត បានកំណត់ពាក្យ ហិង្សា ថាជា ការបៀតបៀន ការធ្វើអាក្រក់រកគ្នា ការធ្វើទុក្ខគ្នា។ ក្រមព្រហ្មទណ្ឌពុំបានឱ្យនិយមន័យក៏ដោយ ក៏គេអាចកំណត់បានថា អំពើហិង្សា ជាការប្រព្រឹត្តដោយចេតនាធ្វើឱ្យជនណាមួយរងរបួស។ឧទាហរណ៍ៈការវាយតប់ ទាត់ធាក់ កាប់ ចាក់.....។

-ការចាត់ទុកជាអំពើហិង្សាដោយចេតនា

មាត្រា ២២៥.ការចាត់ទុកការប្រើសារជាតិពុលដូចជាអំពើហិង្សាដោយចេតនា

តាមមាត្រា ២២៥ អំពើដែលឱ្យអ្នកដទៃផឹក លេប ឬបញ្ចូលទៅក្នុងខ្លួនអ្នកដទៃ តាមមធ្យោបាយណាក៏ដោយ ដោយចេតនានូវសារជាតិពុលដែលបណ្តាលឱ្យខូចសុខភាព ត្រូវចាត់ទុកជាអំពើហិង្សាដោយចេតនា ។

មាត្រា២២៦.ការចាត់ទុកការផ្តល់អាហារដែលមានសារជាតិពុលដូចជា អំពើហិង្សាដោយចេតនា

អំពើលក់ ធ្វើអនុប្បទាន ឬឱ្យចំណី ឬភេសជ្ជៈ ដោយដឹងថាចំណី ឬភេសជ្ជៈនោះ មានសារជាតិពុលនាំឱ្យខូចសុខភាពនោះ ត្រូវចាត់ទុកជាអំពើហិង្សាដោយចេតនា ។

មាត្រា ២២៧.ការចាត់ទុកការបញ្ចូលសារជាតិពុល ក្នុងទឹកសម្រាប់បរិភោគដូចជា អំពើហិង្សាដោយចេតនា

អំពើប្រព្រឹត្តឡើងដោយចេតនា ដោយដាក់បញ្ចូលនូវសារជាតិពុលនាំឱ្យខូច សុខភាពទៅក្នុងទឹកសម្រាប់ហូបជាសាធារណៈ ត្រូវចាត់ទុកជាអំពើហិង្សាដោយ ចេតនា ។

**២.ធាតុផ្សំបទល្មើស**

**២.១.ធាតុនីត្យានុកូល** មាត្រា ២១៧.បទហិង្សាដោយចេតនា

អំពើហិង្សាប្រព្រឹត្តដោយចេតនាលើអ្នកដទៃ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**២.២.ធាតុសត្យានុម័ត**

រាល់អំពើសកម្ម ទាំងឡាយណា ដែលបណ្តាលឱ្យ ប៉ះពាល់ផ្ទាល់ ដល់រាងកាយ ឬ សុខភាព

ជនណាមួយ ទោះបីមានរបួសធ្ងន់ ឬស្រាល ឬបណ្ដាលឱ្យជនរងគ្រោះស្លាប់ ដោយគ្មានចេតនាសម្លាប់ ត្រូវចាត់ទុកជាបទហិង្សាដោយចេតនា ។ អំពើនេះត្រូវតែមាន ការប៉ះពាល់ដល់រាងកាយ ហើយគ្មានការប៉ុនប៉ងទេ ។

**២.៣.ធាតុអត្តនោម័ត**

ជនប្រព្រឹត្តមានចេតនាត្រឹមតែ បង្កឱ្យជនរងគ្រោះ មានរបួស ឬខូចសុខភាព។

**៣.ទោស**

**៣.១.អំពីទោស**

តាមមាត្រា ២១៧ អំពើហិង្សាប្រព្រឹត្តដោយចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**៣.២.ស្ថានទម្ងន់ទោស**

**ក.ស្ថានម្ងន់ទាក់ទង ការគិតទុកជាមុន ការប្រើអាវុធ គំរាមកំហែងនឹងអាវុធ ឬមានការចូលរួមច្រើន**

ការប្រព្រឹត្តបទហិង្សាដោយមាន គិតទុកជាមុន ឬដោប្រើអាវុធ គំរាមកំហែងនឹងអាវុធ ឬមានបក្សពួកច្រើនចូលរួម ត្រូវមានស្ថានទម្ងន់ទោសតាមមាត្រា ២១៨ ក្រមព្រហ្មទណ្ឌ។

មាត្រា ២១៨.ស្ថានទម្ងន់ទោស

អំពើហិង្សាដោយចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល កាលបើអំពើហិង្សានេះបានប្រព្រឹត្ត ៖

១-ដោយមានការគិតទុកជាមុន ។

២-ដោយប្រើអាវុធ ឬគំរាមកំហែងនឹងអាវុធ ។

៣-ដោយមានមនុស្សច្រើននាក់ក្នុងឋានៈជាចារី សហចារី អ្នកផ្តើមគំនិត និង ជាអ្នកសមគំនិត ។

**ខ.ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ**

រាល់ការប្រព្រឹត្តបទហិង្សាទៅលើជនរងគ្រោះ ជាបុគ្គលទន់ខ្សោយដោយសារ ៖ អាយុ ដោយសារជំងឺ-ឬពិការភាព ឬទៅលើ នារីមានគក៏ ដោយមានចេតនាបានដឹង ឬបានឃើញជាមុន ត្រូវមានស្ថានទម្ងន់ទោស តាមមាត្រា ២១៩ នៃក្រមព្រហ្មទណ្ឌ។

មាត្រា ២១៩.ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ

អំពើហិង្សាដោយចេតនាត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំនិងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន)រៀលទៅ១០.០០០.០០០ (ដប់លាន) រៀល កាលបើអំពើហិង្សានេះត្រូវបានប្រព្រឹត្តទៅលើៈ

១-បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុអាយុនៃបុគ្គលនោះ ។

២-នារីមានគភ៌ កាលបើគភ៌ត្រូវបានគេឃើញជាក់ស្តែង ឬកាលបើជនល្មើស បានដឹង ។

៣-បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុនៃជំងឺ ឬពិការភាព កាលបើស្ថានភាពបុគ្គលនេះត្រូវបានគេឃើញជាក់ស្តែង ឬកាលបើជនល្មើសបានដឹង ។

**គ.ស្ថានទម្ងន់ទោសដោយសារគោលដៅ**

រាល់ការប្រព្រឹត្តបទហិង្សាទៅលើ ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី ឬ សាក្សី គោលបំណងៈ រារាំងកុំឱ្យប្តឹងបរិហារពីបទល្មើស កុំឱ្យទាមទារសំណង កុំឱ្យផ្តល់កស្តុតាង ឬខឹងនឹងជនរងគ្រោះប្តឹង សាក្សីបានផ្តល់កស្តុតាងត្រូវមានស្ថានទម្ងន់ទោស តាមមាត្រា ២២០ ក្រមប្រហ្មទណ្ឌ។

មាត្រា ២២០.ស្ថានទម្ងន់ទោសដោយសារគោលដៅ

អំពើហិង្សាដោយចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល កាលបើអំពើនេះ ត្រូវបានប្រព្រឹត្តទៅលើ ៖

១-ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីរារាំងជននេះកុំឱ្យប្តឹងបរិហារ ពីបទល្មើស ឬសុំឱ្យធ្វើការជួសជុលព្យសនកម្ម ។

២-សាក្សី ដើម្បីរារាំងកុំឱ្យឆ្លើយផ្តល់កស្តុតាងនៅពេល ស៊ើបអង្កេត ស៊ើបសួរ សវនាការ ឬនៅក្នុងនីតិវិធីនៃបណ្តឹងផ្សេងទៀត ។

៣-ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី ពីព្រោះជននេះបានបរិហារពី បទល្មើស ឬសុំឱ្យជួសជុលព្យសនកម្ម ។

៤-សាក្សី ដោយមូលហេតុសាក្សីនេះបានផ្តល់កស្តុតាងនៅពេលស៊ើបអង្កេត ស៊ើបសួរ សវនាការ ឬនៅក្នុងនីតិវិធីនៃបណ្តឹងផ្សេងទៀត ។

**ឃ.ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនល្មើស**

មានន័យថា បើមន្ត្រីរាជការសធារណៈ បានប្រព្រឹត្ត បទហិង្សាដោយចេតនា នៅក្នុងក្របខណ្ឌនៃមុខងារ ឬក្នុងឱកាសបំពេញការងារ ត្រូវមានស្ថានទម្ងន់ទោសតាមមាត្រា ២២១ ក្រមព្រហ្មទណ្ឌ។

មាត្រា ២២១. ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនល្មើស

អំពើហិង្សាដោយចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល កាលបើអំពើហិង្សានេះ ត្រូវបានប្រព្រឹត្តដោយ អ្នករាជការសាធារណៈ នៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬនៅក្នុងពេលបំពេញមុខងារ របស់ខ្លួន ។

**ខ.អំពើហិង្សាប្រព្រឹត្តដោយសហព័ទ្ធ ឬអនីតិសង្វាសជន**

រាល់អំពើហិង្សាដោយចេតនាដែលប្រព្រឹត្តដោយ ប្តីទៅលើប្រពន្ធ ឬប្រព្រឹត្តដោយប្រពន្ធទៅលើប្តី ទោះបីរស់នៅជានីតិសង្វាស ឬអនីតិសង្វាសត្រូវមានទោសតាមមាត្រា ២២២ ក្រមព្រហ្មទណ្ឌ។

មាត្រា ២២២. អំពើហិង្សាប្រព្រឹត្តដោយសហព័ទ្ធ ឬអនីតិសង្វាសជន

អំពើហិង្សាដោយចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល កាលបើអំពើហិង្សានេះ ត្រូវបានប្រព្រឹត្តដោយ សហព័ទ្ធ ឬដោយអនីតិសង្វាសជនរបស់ជនរងគ្រោះ ។

**ច.ស្ថានទម្ងន់ទោសដោយសារការកាត់អវយវៈ ឬពិការភាព**

ការប្រព្រឹត្ត បទហិង្សាដោយចេតនា បណ្តាលឱ្យជនរងគ្រោះ កាត់អវៈយវៈ ឬជនរងគ្រោះពិការភាពជាអចិន្ត្រៃយ៏ ត្រូវមានស្ថានទម្ងន់ទោស។

មាត្រា ២២៣.ស្ថានទម្ងន់ទោសដោយសារការកាត់អវយវៈ ឬពិការភាព

អំពើហិង្សាដោយចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ កាលបើអំពើនេះនាំឱ្យមានការកាត់អវយវៈ ឬឱ្យមានពិការភាពជា អចិន្ត្រៃយ៍ដល់ជនរងគ្រោះ ។

**ឆ.ស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ**

មាត្រា ២២៤.ស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ

អំពើហិង្សាដោយចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ កាលបើអំពើនេះបណ្តាលឱ្យជនរងគ្រោះស្លាប់ ដោយគ្មាន ចេតនាសម្លាប់។

**៣.៣.ទោសបន្ថែម**

មាត្រា ២២៥.ទោសបន្ថែម ៖ ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះអាចត្រូវ បានប្រកាស ៖

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសត្រូវបានប្រព្រឹត្ត នៅក្នុងការប្រកបវិជ្ជាជីវៈ ឬនៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំយ៉ាងច្រើន ចំពោះបទឧក្រិដ្ឋ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ចំពោះ បទមជ្ឈិម ។

៤-ការហាមឃាត់ដល់ទណ្ឌិតបរទេសចំពោះការចូល ឬការស្នាក់នៅក្នុងដែនដី នៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុដទៃទៀត ដែលប្រើសម្រាប់ប្រព្រឹត្ត បទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៦-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

៧-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៨-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៩-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

### ៣.៤.ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

មាត្រា ២៣០.ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែល មានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមនេះ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ២២៦ (ការចាត់ទុកការផ្តល់អាហារដែល មានសារជាតិពុលដូចជា អំពើហិង្សាដោយចេតនា) និងមាត្រា ២២៧ (ការចាត់ទុក ការបញ្ចូលសារជាតិពុលក្នុងទឹកសម្រាប់បរិភោគ ដូចជាអំពើហិង្សាដោយចេតនា) នៃក្រមនេះ ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០(ដប់លាន) រៀល ទៅ ៥០.០០០.០០០ (ហាសិបលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើន ដូចតទៅនេះ ៖

១-ការរំលាយតាមបែបបទកំណត់ដោយមាត្រា ១៧០ (ការរំលាយ និងការ ជម្រះបញ្ជីនៃនីតិបុគ្គល) នៃក្រមនេះ

២-ការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ តាមបែបបទ កំណត់ដោយមាត្រា ១៧១ (ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់ តុលាការ) នៃក្រមនេះ ។

៣-ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយ ឬច្រើន តាមបែបបទកំណត់ ដោយមាត្រា ១៧២ (ការហាមឃាត់ចំពោះការធ្វើសកម្មភាព) នៃក្រមនេះ ។

៤-ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ តាមបែបបទកំណត់ដោយមាត្រា ១៧៣ (ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ) នៃក្រមនេះ ។

៥-ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈដល់ការសន្សំសំចៃតាមបែបបទកំណត់ដោយមាត្រា ១៧៥(ការហាមឃាត់ចំពោះការធ្វើអំពាវនាវជា សាធារណៈឱ្យធ្វើការសន្សំសំចៃ) នៃក្រមនេះ ។

៦-ការបិទគ្រឹះស្ថានដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស តាមបែបបទ កំណត់ដោយមាត្រា ១៧៦(ការបិទគ្រឹះស្ថាន) នៃក្រមនេះ ។

៧-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន ដែលបើកចំហដល់ សាធារណជន ឬដែលប្រើប្រាស់ដោយសាធារណជន តាមបែបបទកំណត់ដោយ មាត្រា ១៧៧(ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន) នៃក្រមនេះ ។

៨-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលប្រើប្រាស់សម្រាប់ប្រព្រឹត្ត បទល្មើស ឬដែលមានគោលដៅសម្រាប់ប្រព្រឹត្តបទល្មើស តាមបែបបទកំណត់ដោយ មាត្រា ១៧៨ (ការរឹបអូសកម្មសិទ្ធិការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និងមាត្រា១៧៩ (ការរឹបអូសនិងសិទ្ធិតតិយជន)នៃក្រមនេះ ។

៩-ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស តាមបែបបទកំណត់ ដោយមាត្រា ១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និង មាត្រា ១៧៩ (ការរឹបអូស និងសិទ្ធិតតិយជន) នៃក្រមនេះ ។

១០-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស តាមបែបបទកំណត់ដោយមាត្រា១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញ ចោលវត្ថុរឹបអូស) និងមាត្រា១៧៩ (ការរឹបអូស និងសិទ្ធិតតិយជន) នៃក្រមនេះ ។

១១-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០ (ការបិទផ្សាយសេចក្តីសម្រេច) នៃក្រមនេះ ។

១២-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬការ ផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយ មាត្រា ១៨១ (ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ជាអាទិ៍) នៃក្រមនេះ។

## ផ្នែកទី៣.ការបង្កឱ្យមានរបួសដោយអចេតនា

### ១.និយមន័យ

តាមមាត្រា ២៣៦ នៃក្រមព្រហ្មទណ្ឌបានឱ្យនិយមន័យថា: បទល្មើសបង្កឱ្យមានរបួសដោយអចេតនា គឺជាអំពើដែលបណ្តាលឱ្យមាន របួសដល់អ្នកដទៃដោយ ៖

១-ការធ្វេសប្រហែស ការមិនប្រុងប្រយ័ត្ន ឬការខ្ជីខ្ជា ដែលបង្កឱ្យមាន អសមត្ថភាពក្នុងការធ្វើការងារស្មើឬលើសពី ៨ (ប្រាំបី) ថ្ងៃ ។

២-ការបំពានលើកាតព្វកិច្ចសន្តិសុខ ឬកាតព្វកិច្ចប្រុងប្រយ័ត្នដែលច្បាប់តម្រូវ។

ឧទាហរណ៍:ម្ចាស់ផ្ទះជាន់លើបានជ្រុះថូផ្កា ធ្លាក់មកត្រូវអ្នកដំណើរបណ្តាលឱ្យរបួស។

## ២.ធាតុផ្សំបទល្មើស

### ២.១.ធាតុនីត្យានុកូល

មាត្រា ២៣៦.បទបង្កឱ្យមានរបួសដោយអចេតនា

បទល្មើសបង្កឱ្យមានរបួសដោយអចេតនា គឺជាអំពើដែលបណ្តាលឱ្យមាន របួសដល់អ្នកដទៃដោយ ៖

១-ការធ្វេសប្រហែស ការមិនប្រុងប្រយ័ត្ន ឬការខ្ជីខ្ជា ដែលបង្កឱ្យមាន អសមត្ថភាពក្នុងការធ្វើការងារស្មើ ឬលើសពី ៨ (ប្រាំបី) ថ្ងៃ ។

២-ការបំពានលើកាតព្វកិច្ចសន្តិសុខ ឬកាតព្វកិច្ចប្រុងប្រយ័ត្នដែលច្បាប់តម្រូវ។

បទបង្កឱ្យមានរបួសដោយអចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំនិងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

### ២.២..ធាតុសត្យានុម័ត

រាល់អំពើនៃ ការធ្វេសប្រហែស ការមិនប្រុងប្រយ័ត្ន ឬការខ្ជីខ្ជា របស់បុគ្គល ឬ ការបំពានលើលើកាតព្វកិច្ចសន្តិសុខ កាតព្វកិច្ចប្រុងប្រយ័ត្នដែលច្បាប់តម្រូវ របស់រូបវន្តបុគ្គល ដែលបង្កឱ្យជនណាមួយ មានរបួស ហើយ អសមត្ថភាពក្នុងការធ្វើការងារស្មើឬលើសពី ៨ (ប្រាំបី) ថ្ងៃ ។

អំពើនេះអាចចោទប្រកាន់បានលុះត្រាតែ ជនរងគ្រោះមានរបួសស្នាម និងអសមត្ថភាពធ្វើការងារចាប់ពី ៨ (ប្រាំបី) ថ្ងៃ ។

### ២.៣.ធាតុអត្តនោម័ត

ជនប្រព្រឹត្តគ្មានចេតនាបង្កឱ្យមានព្យសនកម្មទេ ប៉ុន្តែទង្វើ ធ្វេសប្រហែស មិនប្រុងប្រយ័ត្ន ខ្ជីខ្ជា ឬ ការបំពានលើកាតព្វកិច្ចសន្តិសុខ និងកាតព្វកិច្ចប្រុងប្រយ័ត្នដែលច្បាប់តម្រូវ ។

## ៣.ទោស

### ៣.១.ទោសបទបង្កឱ្យមានរបួសដោយអចេតនា

បទបង្កឱ្យមានរបួសដោយអចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២

(ពីរ) ឆ្នាំនិងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**៣.២.ទោសបន្ថែម**

មាត្រា ២៣៧.ទោសបន្ថែម ៖ ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះអាចត្រូវ បានប្រកាស ៖

១-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្ត នៅក្នុងការប្រកបវិជ្ជាជីវៈ ឬនៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការបើកបរយានយន្ត ទោះបីជាប្រភេទណាក៏ដោយ សម្រាប់ រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការព្យួរលិខិតបើកបរ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៤-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ សម្រាប់ រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៦-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៧-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ សម្រាប់ រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

**៣.៣.ការទទួលខុសត្រូវរបស់នីតិបុគ្គល**

មាត្រា ២៣៨.ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែល មានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមនេះ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ២៣៦ (បទបង្កឱ្យមានរបួសដោយ អចេតនា) នៃក្រមនេះ ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើន ដូចតទៅនេះ ៖

១-ការរំលាយតាមបែបបទកំណត់ដោយមាត្រា ១៧០ (ការរំលាយ និងការ ជម្រះបញ្ជីនៃនីតិបុគ្គល) នៃក្រមនេះ

២-ការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ តាមបែបបទ កំណត់ដោយមាត្រា ១៧១ (ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់ តុលាការ) នៃក្រមនេះ ។

៣-ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយ ឬច្រើន តាមបែបបទកំណត់ ដោយមាត្រា១៧២ (ការហាមឃាត់ចំពោះការធ្វើសកម្មភាព) នៃក្រមនេះ ។

៤-ការបិទគ្រឹះស្ថានដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស តាមបែបបទ កំណត់ដោយមាត្រា ១៧៦ (ការបិទគ្រឹះស្ថាន) នៃក្រមនេះ ។

៥-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន ដែលបើកចំហដល់ សាធារណជន ឬដែលប្រើប្រាស់ដោយសាធារណជន តាមបែបបទកំណត់ដោយ មាត្រា១៧៧ (ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន) នៃក្រមនេះ ។

៦-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០ (ការបិទផ្សាយសេចក្ដីសម្រេច) នៃក្រមនេះ ។

៧-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬការ ផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយ មាត្រា១៨១ (ការផ្សាយសេចក្ដីសម្រេចតាមមធ្យោបាយ ទូរគមនាគមន៍សោតទស្សន៍ ជាអាទិ៍) នៃក្រមនេះ ។

## ផ្នែកទី៤.បទហិង្សាស្រាល

### ១.និយមន័យ

អំពើហិង្សាស្រាល ជាអំពើហិង្សាដោយចេតនា ដែលមិនបណ្ដាលឲ្យជនរងគ្រោះ មានរបួសស្នាមនោះទេ ពីព្រោះការវាយតប់មានលក្ខណៈស្រាល ។

### ២.ធាតុផ្សំបទល្មើស

#### ២.១.ធាតុនីត្យានុកូល

មាត្រា ២២៨ បទហិង្សាស្រាល

អំពើប្រព្រឹត្តទៅលើអ្នកដទៃនូវហិង្សាស្រាល ដែលមិននាំឲ្យមានរបួសទេនោះ ត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ពី ៥០០០ រៀល ទៅ ១០០ ០០០រៀល ។

#### ២.២.ធាតុសត្យានុម័ត

-រាល់អំពើហិង្សា ទៅលើមនុស្ស

-មិនបណ្ដាលឲ្យមានរបួសស្នាម ត្រូវចាត់ជាបទហិង្សាស្រាល ។

**២.៣.ធាតុអត្តនោម័ត**

ជនប្រព្រឹត្តមានចេតនាធ្វើឲ្យជនរងគ្រោះរងនូវការឈឺចាប់ត្រឹមកម្រិតតិចតួច ប៉ុន្តែមិនបង្កឲ្យមានរបួសស្នាមធ្ងន់ធ្ងរទេ។

**៣.ទោស**

បទហិង្សាស្រាលជាបទលហុដែលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥000 រៀលទៅ ១00 000 រៀល ។

## ជំពូកទី៤

## ការបំពានខាងផ្លូវភេទ

**ផ្នែកទី១.បទរំលោភសេពសន្ថវៈ**

## ១.និយមន័យ

តាមមាត្រា ២៣៩ ក្រមព្រហ្មទណ្ឌបានឱ្យនិយមន័យថា:គ្រប់អំពើបញ្ចូលអង្គជាត តាមបែបណាក៏ដោយ ឬអំពើបញ្ចូលឧបករណ៍ណាមួយទៅក្នុង អង្គជាត ដែលប្រព្រឹត្តទៅលើអ្នកដទៃ ទោះបីមានភេទដូចគ្នា ឬមិនដូចគ្នាក៏ដោយ ដោយការប្រើហិង្សា ការបង្ខិតបង្ខំ ការគំរាមកំហែង ឬដោយការឆ្លក់ ឱកាស គឺជាបទរំលោភសេពសន្ថវៈ ។

## ២.ធាតុផ្សំនៃបទរំលោភសេពសន្ថវៈ

បទរំលោភសេពសន្ថវៈគឺជាបទល្មើសព្រហ្មទណ្ឌ។ ជាទូទៅបទល្មើសព្រហ្មទណ្ឌ មានធាតុផ្សំបីគឺ ធាតុនីត្យានុកូល ធាតុសត្យានុមត័ និង ធាតុអត្តនោមត័ ។

### ២.១.ធាតុនីត្យានុកូល

ដើម្បីកំណត់អំពើណាមួួយជាបទល្មើសបាន លុះត្រាតែអំពើនោះមានច្បាប់ចែងច្បាស់លាស់ ។ អំពើរួមភេទជាមួយជនដែលមានអាយុចាប់ពី ១៥ឆ្នាំឡើង មិនចាត់ទុកជាបទល្មើសទេ ។ ចំពោះការរួមភេទដោយ ការប្រើហិង្សា ការបង្ខិតបង្ខំ ការគំរាមកំហែង ឬដោយការឆ្លក់ឱកាស ត្រូវបានហាមឃាត់ដោយច្បាប់ ហើយបានកំណត់ជាបទឧក្រិដ្ឋគឺ បទរំលោភសេពសន្ថវៈ។

មាត្រា ២៣៩. បទរំលោភសេពសន្ថវៈ

គ្រប់អំពើបញ្ចូលអង្គជាត តាមបែបណាក៏ដោយ ឬអំពើបញ្ចូលឧបករណ៍ ណាមួយទៅក្នុងអង្គជាត ដែលប្រព្រឹត្តទៅលើអ្នកដទៃ ទោះបីមានភេទដូចគ្នា ឬមិន ដូចគ្នាក៏ដោយ ដោយការប្រើហិង្សា ការបង្ខិតបង្ខំ ការគំរាមកំហែង ឬដោយការឆ្លក់ ឱកាស គឺជាបទរំលោភសេពសន្ថវៈ ។

បទរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ។

នីតិភាពនៃការរួមភេទត្រូវបានកំណត់ចាប់ពីអាយុ ១៥ (ដប់ប្រាំ) ឆ្នាំ ឡើងទៅ ។

### ២.២.ធាតុសត្យានុមត័

អំពើដែលបានប្បញ្ញត្តិនៅក្នុងមាត្រា ២៣៩ ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ មានបួនប្រភេទ ដើម្បីចាត់ទុកជា អំពើរំលោភសេពសន្ថវៈ ហើយជនប្រព្រឹត្តត្រូវទទួលទោស ពីបទរំលោភសេពសន្ថវៈគឺ: ការប្រើហិង្សា ការបង្ខិតបង្ខំ ការគំរាមកំហែងឬ ការឆ្លក់ឱកាស ដើម្បីបញ្ចូលអង្គជាត ឬបញ្ចូលឧបករណ៏ណាមួយ ទៅក្នុងអង្គជាតអ្នកដ៏ទៃ។

**ក.ការប្រើហិង្សា:** ដើម្បីប្រព្រឹត្តបទរំលោភបានសំរេចជនល្មើសភាគច្រើន ប្រើហិង្សា ទៅលើជន

រងគ្រោះ គោលដៅបង្ក្រាបការតបត ពីជនរងគ្រោះ ហើយអំពើខ្លះ អាចបណ្តាលឱ្យ ជនរងគ្រោះ ស្លាប់ ពិការ របួស ។ អំពើហិង្សានេះជនល្មើសស្តែងឡើងតាមរយៈការប្រើប្រាស់អាវុធ ឬគ្មានការប្រើអាវុធ បានវាយតប់ លើរាងកាយ បោចសក់ កំពិតមាត់ ច្របាច់ក អុកក្បាល់ មូលដៃ អុកភ្លៅ ទ្រូង..របស់ ជនរងគ្រោះ (ហិង្សាលើរាងកាយ) ។

**ខ.ការបង្ខិតបង្ខំ:** អំពើបង្ខិតបង្ខំនេះជនល្មើស ស្តែងឡើងតាមរយៈ ការប្រើអាវុធ ឬគ្មានការប្រើ អាវុធ ឬប្រើកំលាំង ទៅលើជនរងគ្រោះ ក្នុងគោលដៅឱ្យ ជនរងគ្រោះ ស្ថិតក្នុងស្ថានភាពទ័លច្រក ផ្អែកស្មារតី។ ជនល្មើស ភាគច្រើនប្រព្រឹត្ត ទៅលើជនរងគ្រោះដែលមានកំលាំង ឬ សតិខ្សោយជាងដូច ជា អនីតិជន ជនងាយរងគ្រោះ ជនមានជំងឺ ឬជនមានសតិវិបល្លាស ឬពិការរាងកាយ ...។ អំពើនេះ ជនប្រព្រឹត្តច្រើនជ្រើសយក កន្លែងកើតហេតុប្រកប ដោយគ្រោះថ្នាក់ ទីស្ងាត់ ឬ អាថ៌កំបាំង ឬ ពេលជនរងគ្រោះស្ថិត ក្នុងស្ថានភាពឯកោ មិនមានជំរើស ក្នុងការទប់ទល់នឹងឈ្លានពាន។

**គ.ការគំរាមកំហែង:** ជាអំពើសំខាន់មួយក្នុងធាតុសត្យានុមត័ ដើម្បីកំណត់បទល្មើសរំលោភសេពសន្ថវៈ។អំពើនេះស្តែងឡើងដោយមានអាវុធ ឬគ្មានអាវុធ តាមរយៈ ពាក្យសំដី កាយវិការ ឬប្រើប្រាស់ អំណាចដើម្បី បំភិតបំភ័យ បំបាក់ស្មារតី ឬគាបសង្កត់ទៅលើ ផ្លូវចិត្តជនរងគ្រោះ ក្នុងពេល និងក្រោយពេល រំលោភសេពសន្ថវៈ។

**ឃ.ការឆ្មក់ឱកាស:**ការឆ្មក់ឱកាសជាអំពើស្តែងឡើងតាមរយការប្រើប្រាស់មធ្យោបាយ ឬឧបាយកលឬការលបប្រព្រឹត្តក្នុងកាលៈទេសៈផ្សេងៗ ដូចជា: ធ្វើអោយស្ត្រីភាន់ច្រឡំថាប្តីខ្លួន ឬដាក់ថ្នាំសណ្តំ ថ្នាំសម្រើប ថ្នាំវង្វេងស្មាតី ឬជនរងគ្រោះស្ថិតក្នុងស្ថានភាពស្រវឹងស្រា កំពុងលង់លក់ ។

**២.៣.ធាតុអត្តនោមត័**

គោលបំណងនៃធាតុផ្សំអត្តនោមត័ គឺជាការវែកញែក រវាងអំពើប្រព្រឹត្តដោយ ចេតនា ឬ ដោយ អចេតនា ដើម្បីកំណត់បទល្មើស និងទោសឱ្យបានត្រឹមត្រូវ។ការរំលោភសេពន្ថវៈ ជាការប្រព្រឹត្តដោយ ចេតនា ដូច្នេះដើម្បីឱ្យជនប្រព្រឹត្តអំពើនេះទទួលខុសត្រូវព្រហ្មទណ្ឌច្បាប់តម្រូវឱ្យ:

-ជនប្រព្រឹត្តមានសតិសម្បជញ្ញៈ ដោយដឹងថាអំពើដែលខ្លួនប្រព្រឹត្តជា បទល្មើសដែលច្បាប់ហាមឃាត់ ។

-ដឹងពីទំហំនៃព្យសនកម្មដែលខ្លួនបង្កឡើង (ជនរងគ្រោះអាចស្លាប់ ពិការភាព របួសរាងកាយ ផ្លូវភេទ ភយ័ខ្លាចខូចកេត្តិយស សេចក្តីថ្លៃថ្នូរ...។

-ជាជនមានសមត្ថភាពទទួលខុសត្រូវតាមផ្លូវច្បាប់ (អាយុចាប់ពី១៨ឆ្នាំឡើង)។

**៣.អំពីទោស**

ច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ចែងនៅមាត្រា ៣៣ បានកំណត់អំពីទោស នៃបទរំលោភសេពសន្ថវៈ ជាបទឧក្រិដ្ឋ ដាក់ពន្ធនាគារពី ៥ ឆ្នាំទៅ ១០ឆ្នាំ ។ ហើយមានស្ថានទម្ងន់ទោស ដាក់ពន្ធនាគារពី ១០ឆ្នាំទៅ១៥ឆ្នាំក្នុងករណី: ការប្រព្រឹត្តដោយការគំរាមកំហែងនឹង អាវុធ ទៅលើស្ត្រីមានផ្ទៃពោះ លើជនមានជំងឺឬជនមានសតិវិបល្លាស ឬពិការរាងកាយ ឬ ធ្វើឡើងដោយមានអ្នកប្រព្រឹត្ត ពីរនាក់ ឬច្រើននាក់ ឬដោយមានអ្នកសមគំនិត ឬបើការសេពសន្ថវៈត្រូវធ្វើឡើងដោយជនដែលមានអំណាចលើអ្នករងគ្រោះ។

ច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ:ចុះថ្ងៃទី ៧ខែមករាឆ្នាំ២០០២ ប្បញ្ញត្តិក្នុង មាត្រា៥ បានកំណត់អំពីទោសនៃ បទរំលោភសេពសន្ថវៈជាបទឧក្រិដ្ឋ ដាក់ពន្ធនាគារពី ១០ ឆ្នាំ ទៅ ១៥ ឆ្នាំ។ ហើយមានស្ថានទម្ងន់ទោសដាក់ពន្ធនាគារពី ១៥ ឆ្នាំ ទៅ២០ឆ្នាំក្នុងករណី: ការប្រព្រឹត្តដោយការគំរាមកំហែងដោយអាវុធទៅលើ ស្ត្រីមានផ្ទៃពោះ លើជនមានជំងឺ ឬជនមានសតិវិបល្លាស ឬពិការរាងកាយ ឬលើអនីតិជនអាយុតិចជាង១៨ឆ្នាំធ្វើឡើង ដោយមានអ្នកប្រព្រឹត្តម្នាក់ ឬច្រើននាក់ ឬដោយអ្នកសមគំនិត ឬបើការសេពសន្ថវៈត្រូវធ្វើឡើងដោយ ជនដែលមានអំណាចលើអ្នករងគ្រោះ។

តាមក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ បានកំណត់អំពីទោសនៃទរំលោភសេពសន្ថវៈ ជាបទឧក្រិដ្ឋដោយដាក់ពន្ធនាគារពី ៥ ឆ្នាំ ទៅ ១០ឆ្នាំ ហើយមានស្ថានទម្ងន់ទោសដាក់ពន្ធនាគាររហូតដល់៣០ឆ្នាំ និងមានទោសបន្ថែមទៀត។

**៣.១.អំពីទោសបទរំលោភសេពសន្ថវៈ**

មាត្រា២៣៩៖បទរំលោភសេពសន្ថវៈ បទរំលោភសេពសន្ថវៈត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ទៅ ១០ឆ្នាំ។

**៣.២.អំពីស្ថានទម្ងន់ទោស**

**ក.ស្ថានទម្ងន់ទោសដោយសារមធ្យោបាយប្រើប្រាស់ឬទាក់ទងនឹងជនល្មើស**

មាត្រា២៤០៖ ស្ថានទម្ងន់ទោសដោយសារមធ្យោបាយប្រើប្រាស់ឬទាក់ទងនឹងជនល្មើស

បទរំលោភសេពសន្ថវៈត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ឆ្នាំ ទៅ១៥ឆ្នាំ កាលបើបទល្មើសនេះប្រព្រឹត្តឡើង:

១.ដោយការប្រើអាវុធឬ គំរាមកំហែងនឹងអាវុធ ។

២.ដោយការប្រើគ្រឿងញៀន ឬគ្រប់វិធីដែលនាំឱ្យជនរងគ្រោះបាត់បង់ ឬចុះខ្សោយលទ្ធភាពទប់ទល់

៣.ដោយបុគ្គល់ដែលមានអំណាចទៅលើជនរងគ្រោះ។

៤.ដោយបុគ្គលដែលរំលោភអំណាចដែលមុខងាររបស់ខ្លួនបានប្រគល់ឱ្យ។

៥.ដោយបុគ្គលច្រើនរូបដែលប្រព្រឹត្តឡើងក្នុងឋានៈ ជាចារី សហចារី អ្នកផ្ដើមគំនិតឬ ជាអ្នកសមគំនិត

**ខ.ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ**

មាត្រា២៤១៖ ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ

បទរំលោភសេពសន្ថវៈត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៧ឆ្នាំ ទៅ១៥ឆ្នាំកាលបើអំពើនេះប្រព្រឹត្តទៅលើ:

១.បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុអាយុនៃបុគ្គលនោះ។

២.នារីមានគភ៌ កាលបើគភ៌ត្រូវបានគេឃើញជាក់ស្ដែងឬកាលបើជនល្មើសបានដឹង។

៣.បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុនៃជំងឺ ឬពិការភាព កាលបើស្ថានភាពបុគ្គលនេះត្រូវបានគេឃើញ ជាក់ស្ដែងឬកាលបើជនល្មើសបានដឹង។

**គ.ស្ថានទម្ងន់ទោសដោយសារការកាត់អវយវៈ ឬពិការភាព**

មាត្រា២៤២៖ស្ថានទម្ងន់ទោសដោយសារការកាត់អវយវៈ ឬពិការភាព

បទរំលោភសេពសន្ថវៈត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី១០ឆ្នាំ ទៅ២០ឆ្នាំ កាលបើបទល្មើសនេះនាំឱ្យមានការ កាត់ អវយវៈ ឬពិការភាព ជាអចិន្ត្រៃយ៍ដល់ជនរងគ្រោះ។

**ឃ.ស្ថានទម្ងន់ទោសដោយសារការធ្វើទារុណកម្ម ឬ អំពើឃោរឃៅ**

មាត្រា២៤៣ ស្ថានទម្ងន់ទោសដោយសារការធ្វើទារុណកម្ម ឬ អំពើឃោរឃៅ

បទរំលោភសេពសន្ថវៈត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី១០ឆ្នាំ ទៅ៣០ឆ្នាំ កាលបើបទល្មើសនេះប្រព្រឹត្តឡើងមុន ពេល ក្នុងពេល ឬក្រោយពេល ប្រព្រឹត្តអំពើ ទារុណកម្ម ឬ អំពើឃោរឃៅ។

**ង.ស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ**

មាត្រា២៤៤ ស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ

បទរំលោភសេពសន្ថវៈត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១៥ឆ្នាំ ទៅ៣០ឆ្នាំ កាលបើបទល្មើសនេះបណ្តាលឱ្យជនរងគ្រោះស្លាប់ ដោយគ្មានចេតនាសម្លាប់។

**៤.អំពីទោសបន្ថែម:**

មាត្រា២៩៥ ទោសបន្ថែម: ប្រភេទ និងរយៈពេល

ចំពោះបទឧក្រិដ្ឋដែលមានចែងក្នុង ផ្នែកនេះ ទោសបន្ថែមដូចតទៅ អាចត្រូវបានប្រកាស:

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះ បានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈឬនៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះជាស្ថាពរ ឬសម្រាប់រយៈពេល៥ឆ្នាំយ៉ាងច្រើន។

៣-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល១០ឆ្នាំយ៉ាងច្រើន។

៤-ការហាមឃាត់ដល់ទណ្ឌិតបរទេសចំពោះការចូលឬការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ស្ថាពរ ឬសម្រាប់រយៈពេល៥ឆ្នាំយ៉ាងច្រើន។

៥-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះនិងគ្រាប់រំសេវគ្រប់ប្រភេទជាស្ថាពរ ឬសម្រាប់រយៈពេល៥ឆ្នាំយ៉ាងច្រើន។

៦-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ខែយ៉ាងច្រើន។

៧- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស នៅក្នុងសារពត៏មាន។

៨-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៏ សោតទស្សន៏សម្រាប់រយៈពេល ៨ថ្ងៃយ៉ាងច្រើន។

**ផ្នែកទី២.បទប្រទូស្តកេរខ្មាស**

**១.និយមន័យ**

តាមមាត្រា២៩៦ នៃក្រមព្រហ្មទណ្ឌបានឱ្យនិយមន័យថា: គ្រប់អំពើ ប៉ះពាល់ ស្ទាប អង្អែល កេរភេទ ឬផ្នែកភេទផ្សេងទៀតរបស់ បុគ្គលដទៃ តែបុគ្គលនេះ មិនស្រ្វគផងទេ ឬបង្ខំបុគ្គលដទៃឱ្យប្រព្រឹត្តអំពើនេះមកលើ ខ្លួនឬទៅលើតតិយបុគ្គល ក្នុងគោលបំណងធ្វើឱ្យរំជួល ឬរីករាយដល់ចំណង់ផ្លូវភេទរបស់ជនល្មើស គឺជាអំពើប្រទូស្តកេរខ្មាស។

**២.ធាតុផ្សំបទល្មើស**

**២.១.ធាតុនីត្យានុកូល**

មាត្រា ២៤៦.បទប្រទូស្តកេរខ្មាស

អំពើប្រទូស្តកេរខ្មាស ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និង ពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**២.២.ធាតុសត្យានុម័ត**

-រាល់អំពើប្រព្រឹត្តដោយចេតនាដើម្បី ប៉ះពាល់ ស្ទាប អង្អែលកេរភេទ ឬផ្នែកភេទ របស់បុគ្គលដទៃ

-ផ្ទុយពីឆន្ទៈជនរងគ្រោះ ឬបង្ខំជនរងគ្រោះឱ្យប្រព្រឹត្តអំពើនេះមកលើ ខ្លួនឬទៅលើតតិយបុគ្គល

-ក្នុងគោលបំណងធ្វើឱ្យរំជួល ឬរីករាយដល់ចំណង់ផ្លូវភេទរបស់ជនល្មើស ។

**២.៣.ធាតុអត្តនោម័ត**

ជនល្មើសយល់ដឹងថា អំពើនោះជាអំពើអសីលធម៌ ប៉ះពាល់ដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះ ប៉ុន្តែជនល្មើសនៅតែមានចេតនា ប្រព្រឹត្ត ដើម្បីធ្វើឱ្យរំជួល ឬរីករាយដល់ចំណង់ផ្លូវភេទរបស់ខ្លួន។

**៣.ទោស**

**៣.១.ទោសបទប្រទូស្តកេរខ្មាស**

អំពើប្រទូស្តកេរខ្មាស ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និង ពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**៣.២.ស្ថានទម្ងន់ទោស**

**ក.ស្ថានទម្ងន់ទោសដោយសារមធ្យោបាយប្រើប្រាស់ ឬទាក់ទងនឹងចារី**

មាត្រា ២៤៧.ស្ថានទម្ងន់ទោសដោយសារមធ្យោបាយប្រើប្រាស់ ឬទាក់ទងនឹងចារី

បទល្មើសដែលមានចែងក្នុងមាត្រា ២៤៦ (បទប្រទូស្តកេរខ្មាស) នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល កាលបើ អំពើនេះ ប្រព្រឹត្តឡើង ៖

១-ដោយការប្រើអាវុធ ឬការគំរាមកំហែងនឹងអាវុធ ។

២-ដោយការប្រើគ្រឿងញៀន ឬគ្រប់វិធីដែលនាំឱ្យជនរងគ្រោះបាត់បង់ ឬចុះខ្សោយលទ្ធភាពទប់ទល់ ។

៣-ដោយបុគ្គលដែលមានអំណាចទៅលើជនរងគ្រោះ ។

៤-ដោយបុគ្គលដែលរំលោភអំណាច ដែលមុខងាររបស់ខ្លួនបានប្រគល់ឱ្យ ។

៥-ដោយបុគ្គលច្រើនរូប ដែលប្រព្រឹត្តឡើងក្នុងឋានៈជា ចារី សហចារី អ្នកផ្ដើមគំនិត ឬ ជាអ្នកសមគំនិត ។

**ខ.ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ**

មាត្រា ២៤៨.ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ

បទល្មើសដែលមានចែងក្នុងមាត្រា ២៤៦ (បទប្រទូស្តកេរខ្មាស)នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់

ពន្ធនាគារពី ២(ពីរ) ឆ្នាំ ទៅ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀលកាលបើអំពើនេះប្រព្រឹត្តទៅលើ ៖

១-បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុអាយុនៃបុគ្គលនោះ ។

២-នារីមានគភ៌ កាលបើគភ៌ត្រូវបានគេឃើញជាក់ស្តែង ឬកាលបើជនល្មើស បានដឹង ។

៣-បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុនៃ ជំងឺ ឬពិការភាព កាលបើស្ថានភាពបុគ្គលនេះត្រូវបានគេឃើញជាក់ស្តែង ឬកាលបើជនល្មើសបានដឹង។

**៤.ទោសបន្ថែម**

មាត្រា ២៥២.ទោសបន្ថែម ៖ ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវ បានប្រកាស ៖

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្ត នៅក្នុងការប្រកបវិជ្ជាជីវៈ ឬនៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៤-ការហាមឃាត់ដល់ទណ្ឌិតបរទេសចំពោះការចូល ឬការស្នាក់នៅក្នុងដែនដី នៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

៦-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៧-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មាន ។

៨-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ផ្នែកទី៣.បទបង្ហាញកេរភេទ

### ១.និយមន័យ

បទបង្ហាញកេរភេទ ជាអំពើបង្ហាញកេរភេទរបស់ខ្លួនឯង នៅទីកន្លែងសាធារណៈ ដោយមានចេតនាឱ្យអ្នកដទៃមើលឃើញ ។

### ២.ធាតុផ្សំបទល្មើស

#### ២.១.ធាតុនីត្យានុកូល

មាត្រា ២៤៩.បទបង្ហាញកេរភេទ

អំពើបង្ហាញកេរភេទដែលនាំឱ្យអ្នកដទៃមើលឃើញ នៅក្នុងទីកន្លែងមួយដែល សាធារណជនអាចមើលឃើញ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ថ្ងៃ ទៅ ៣ (បី) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ៥០០.០០០ (ប្រាំសែន) រៀល ។

#### ២.២.ធាតុសត្យានុម័ត

-អំពើបង្ហាញកេរភេទខ្លួនឯង

-នៅទីកន្លែងសាធារណៈ

-មានចេតនាឲ្យសាធារណៈជនមើលឃើញ

#### ២.៣.ធាតុអត្ថនោម័ត

មានឆន្ទះចង់ឲ្យអ្នកដទៃមើលឃើញកេរភេទរបស់ខ្លួន ។

### ៣.ទោស

អំពើបង្ហាញកេរភេទត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ថ្ងៃ ទៅ ៣ (បី) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ៥០០.០០០ (ប្រាំសែន) រៀល ។

### ៤.ទោសបន្ថែម

មាត្រា ២៥២.ទោសបន្ថែម ៖ ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវ បានប្រកាស ៖

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្ត នៅក្នុងការប្រកបវិជ្ជាជីវៈ ឬនៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៤-ការហាមឃាត់ដល់ទណ្ឌិតបរទេសចំពោះការចូល ឬការស្នាក់នៅក្នុងដែនដី នៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

៦-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៧-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៨-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ផ្នែកទី៤.បទរុករកួនខាងផ្លូវភេទ

### ១.និយមន័យ

អំពើរុករកួនខាងផ្លូវភេទ គឺជាអំពើដែលបុគ្គលម្នាក់រំលោភអំណាច ដែលមុខងាររបស់ខ្លួនប្រគល់ឱ្យ ធ្វើការគាបសង្កត់ម្តងហើយម្តងទៀតទៅលើអ្នកដទៃ ក្នុងគោលបំណងទទួលការអនុគ្រោះខាងផ្លូវភេទ ។

### ២.ធាតុផ្សំបទល្មើស

#### ២.១.ធាតុនីត្យានុកូល

មាត្រា ២៥០. បទរុករកួនខាងផ្លូវភេទ

អំពើរុករកួនខាងផ្លូវភេទគឺជាអំពើដែលបុគ្គលម្នាក់រំលោភអំណាចដែលមុខងាររបស់ខ្លួនប្រគល់ឱ្យ ធ្វើការគាបសង្កត់ម្តងហើយ ម្តងទៀតទៅលើអ្នកដទៃ ក្នុង គោលបំណងទទួល ការអនុគ្រោះខាងផ្លូវភេទ ។

អំពើរុកកួនខាងផ្លូវភេទ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ថ្ងៃ ទៅ ៣ (បី) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ៥០០.០០០ (ប្រាំសែន) រៀល ។

**២.២.ធាតុសម្ភារនុម័ត**

-អំពើៈរបស់បុគ្គលដែលមានអំណាចដែលមុខងាររបស់ខ្លួនប្រគល់ឲ្យ

-សកម្មភាពៈ បុគ្គលនោះរំលោភអំណាចរបស់ខ្លួន

-មធ្យោបាយៈរុកកួន(ទាមទារ) ម្តងហើយម្តងទៀត តាមរយៈ ការគាបសង្កត់នៃមុខងារ

-ទៅលើជនក្រោមអំណាចខ្លួន

-គោលបំណងៈ ទទួលបាន  ការអនុគ្រោះខាងផ្លូវភេទ ។

**២.៣.ធាតុអត្តនោម័ត**

មានចេតនា ក្នុងការរុកកួន ដើម្បីជំរិតទារយកបានការអនុគ្រោះខាងផ្លូវភេទ ។

**៣.ទោស**

អំពើរុកកួនខាងផ្លូវភេទ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ថ្ងៃ ទៅ ៣ (បី) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ៥០០.០០០ (ប្រាំសែន) រៀល ។

**៤.ទោសបន្ថែម**

មាត្រា ២៥២.ទោសបន្ថែម ៖ ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវ បានប្រកាស ៖

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ   កាលបើបទល្មើសនេះបានប្រព្រឹត្ត នៅក្នុងការប្រកបវិជ្ជាជីវៈ ឬនៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៤-ការហាមឃាត់ដល់ទណ្ឌិតបរទេសចំពោះការចូល ឬការស្នាក់នៅក្នុងដែនដី     នៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការហាមឃាត់ចំពោះការកាន់កាប់  ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ   និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

៦-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៧-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៨-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី៥
## ការយកទ្រព្យសម្បត្តិអ្នកដទៃ

មាត្រា ៤៤ នៃរដ្ឋធម្មនុញ្ញបានគាំពារកម្មសិទ្ធិឯកជនស្របច្បាប់ ហើយនៅក្នុងគន្ថីទី៣ ចាប់ពីមាត្រា ៣៥៣ នៃក្រមព្រហ្មទណ្ឌ បានចែងប្រឆាំងទៅនឹង ការរំលោភបំពានដោយខុសច្បាប់ ទៅលើកម្មសិទ្ធឯកជន និងទ្រព្យសម្បត្តិសាធារណៈ ដោយប្រមូលចងក្រងអំពើរំលោភបំពានមួយចំនួនថាជាបទល្មើសប្រឆាំងនឹងទ្រព្យសម្បត្តិ ។ ក្នុងក្រមព្រហ្មទណ្ឌមានបទល្មើសច្រើនមិនអាចសិក្សាអស់ ដូចនេះយើងលើកយកតែបទល្មើសណា ដែលមានញឹកញាប់នៅក្នុងសង្គម មកសិក្សាតែប៉ុណ្ណោះ។

## ផ្នែកទី១.អំពើលួច

### ១-និយមន័យ

តាមមាត្រា ៣៥៣ នៃក្រមព្រហ្មទណ្ឌបានឱ្យនិយមន័យថា: អំពើលួច គឺជាអំពើឯកឫបាតដោយទុច្ចរិតនូវ ទ្រព្យសម្បត្តិ ឬវត្ថុផ្សេងទៀត របស់អ្នកដទៃតាមគ្រប់មធ្យោបាយ ក្នុងគោលបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ។ ចំណែកមាត្រា ៣៥៤ ក្រមព្រហ្មទណ្ឌ បានចាត់ទុកជាអំពើលួចផងដែរចំពោះអំពើប្រើប្រាស់ដោយទុច្ចរិតនូវថាមពល ដែលនាំឱ្យ ខូចប្រយោជន៍អ្នកដទៃ ។

រីឯអំពើលួចទ្រព្យសម្បត្តិរបស់ បុព្វញាតិ ឬបច្ឆាញាតិ ឬ អំពើលួចទ្រព្យសម្បត្តិរបស់សហព័ទ្ធមិនអាចត្រូវផ្តន្ទាទោសពីបទលួចបានទេ (មាត្រា ៣៥៥ ក្រមព្រហ្មទណ្ឌ)។

### ២-ធាតុផ្សំបទល្មើសលួច

#### ២.១.ធាតុនីត្យានុកូល

មាត្រា ៣៥៦ ក្រមព្រហ្មទណ្ឌអំពើលួច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ ខែ ទៅ៣ (បី) ឆ្នាំ និង ពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលា លាន) រៀល និងអំពើលួចស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សាមាត្រា ៣៥៧ , ស្ថានទម្ងន់ទោសដោយសារមានការកាត់អវយវៈ ឬពិការភាពមាត្រា ៣៥៨ , ស្ថានទម្ងន់ទោសដោយសារការធ្វើទារុណកម្ម ឬអំពើឃោរឃៅមាត្រា ៣៥៩ , ស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ មាត្រា ៣៦០ ចំពោះការប៉ុនប៉ងមានទោស មាត្រា ៣៦១ នៃក្រមព្រហ្មទណ្ឌ ព្រមទាំងអាចប្រកាសទោសបន្ថែមដែលមានចែងក្នុងមាត្រា ៣៦២ ទៀតផង។

#### ២.២.ធាតុសត្យានុម័ត

-ចេតនាទុច្ចរិត: ចារីមានចេតនាចង់បានទ្រព្យសម្បត្តិ ឬវត្ថុ របស់អ្នកដទៃ តាមមធ្យោបាយមិនស្របច្បាប់ ។

-ការដកហូត: ជាការចាប់យកឲ្យមានបំលាស់ទីនៃ ទ្រព្យសម្បត្តិ ឬ វត្ថុ ។ ចំពោះវត្ថុគ្មានរូបរាងការដកហូតអាចកំណត់ទៅលើការ លួចប្រើប្រាស់ថាមពលផងដែរ។ដូចជា: ការរើសបានហើយមិនព្រមប្រគល់ឲ្យទៅម្ចាស់កម្មសិទ្ធិករ , ការដកហូតមិនឲ្យម្ចាស់ដឹង (លួច) ,ការដកហូតនៅចំពោះមុខម្ចាស់កម្មសិទ្ធិករ ឬអ្នកកាន់កាប់តាមរយៈ ការឆក់ ការប្រើហិង្សា , ការគាស់ទំលុះទំលាយ ។ មិនមែនជាបទលួចទេចំពោះការប្រព្រឹត្តទៅលើអចលនវត្ថុដូចជា: យកអគារ , ដីធ្លី , ផ្ទះសំបែង, ដើមឈើនៅជាប់នឹងគល់...។ ប៉ុន្តែគេអាចចោទប្រកាន់ពីបទលួចបានចំពោះ ការដកហូតយកសម្ភារៈដូចជា: ទ្វារបង្អួច , ក្តារ , កម្ជា , ...ឬដើមឈើដែលបានកាត់ចេញពីគល់រួចហើយ ។

-កម្មសិទ្ធិរបស់អ្នកដទៃ: មានន័យថាទ្រព្យដែលដកហូត ឬ លួចប្រើប្រាស់ថាមពល នោះជាកម្មសិទ្ធិអ្នកដទៃ ។ ចំពោះការលួចទ្រព្យសម្បត្តិរបស់ បុព្វញាតិ ឬ បច្ឆាញាតិ ឬអំពើលួចទ្រព្យសម្បត្តិរបស់សហព័ទ្ធ មិនអាចត្រូវផ្តន្ទាទោសពីបទលួចបានទេ ។

-យកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន: គឺយកមកប្រើប្រាស់ អាស្រ័យផល និងចាត់ចែង ។

**២.៣.ធាតុអត្តនោម័ត**

ចារីមានចេតនាទុច្ចរិត ហើយមានសតិសម្បជញ្ញៈ ដោយដឹងថាទ្រព្យសម្បត្តិនោះមិនមែនជាកម្មសិទ្ធិរបស់ខ្លួន ហើយសំដែងកិរិយាដូចជាម្ចាស់ទ្រព្យ។

**៣.ការផ្តន្ទាទោស**

**៣.១.អំពើលួច**

អំពើលួច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ និង ពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយ លាន) រៀល ។

**៣.២.អំពើលួចមានស្ថានទម្ងន់ទោស**

**ក.ស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តប្រើហិង្សា** (មាត្រា ៣៥៧)

អំពើលួច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៣ (បី) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ក្នុងករណីដូចតទៅ ៖

១-អំពើលួចនេះ ប្រព្រឹត្តឡើងមុនពេល ក្នុងពេល ឬក្រោយពេលប្រើហិង្សា ។

២-អំពើលួចនេះ ប្រព្រឹត្តដោយការកាប់គាស់ទម្លុះទម្លាយ

**ខ.ស្ថានទម្ងន់ទោសដោយសារមានការកាត់អវយវៈ ឬពិការភាព** (មាត្រា ៣៥៨)

អំពើលួច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ ប្រសិនបើអំពើនេះ

ប្រព្រឹត្តមុនពេល ក្នុងពេល ឬក្រោយពេលប្រើហិង្សា ដែលនាំឱ្យ មានការកាត់អវយវៈ ឬពិការភាពជាអចិន្ត្រៃយ៍ ។

**គ.ស្ថានទម្ងន់ទោសដោយសារការធ្វើទារុណកម្ម ឬអំពើឃោរឃៅ** (មាត្រា ៣៥៩ )

អំពើលួច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាម សិប) ឆ្នាំ ប្រសិនបើអំពើនេះប្រព្រឹត្តមុនពេល ក្នុងពេល ឬក្រោយពេលប្រើទារុណកម្ម ឬអំពើឃោរឃៅ ។

**ឃ.ស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ** (មាត្រា ៣៦០)

អំពើលួចត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាម សិប) ឆ្នាំ ប្រសិនបើអំពើនេះប្រព្រឹត្តមុនពេល ក្នុងពេល ឬ ក្រោយពេលប្រើហិង្សា ដែលបណ្តាលឱ្យជនរងគ្រោះស្លាប់ដោយគ្មានចេតនាសម្លាប់។

**៤.ទោសបន្ថែម** (មាត្រា ៣៦២)

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះទោសបន្ថែមដូចតទៅនេះអាច ត្រូវបានប្រកាស ៖

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្ត នៅក្នុងការប្រកបវិជ្ជាជីវៈ ឬនៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ ជាស្ថាពរ ឬសម្រាប់ រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

៤-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ចំពោះបទឧក្រិដ្ឋ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ចំពោះ បទមជ្ឈិម ។

៥-ការហាមឃាត់ដល់ទណ្ឌិតបរទេសចំពោះការចូល ឬការស្នាក់នៅក្នុងដែនដី នៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

៦-ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុណាមួយ ដែលប្រើប្រាស់សម្រាប់ប្រព្រឹត្ត បទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៧-ការរឹបអូសវត្ថុ ឬមូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស ។

៨-ការរឹបអូសផលទុន និងទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៩-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុនៅក្នុងទីកន្លែងដែល បទល្មើសនោះបាន

ប្រព្រឹត្ត ។

១០-ការរឹបអូសយានជំនិះរបស់ទណ្ឌិតមួយគ្រឿង ឬច្រើនគ្រឿង ។

១១-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

១២-ការបិទគ្រឹះស្ថានដែលប្រើប្រាស់សម្រាប់ត្រៀម ឬប្រព្រឹត្តបទល្មើស ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

១៣-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន ដែលបើកចំហជូន សាធារណជន ឬដែលប្រើប្រាស់ដោយសាធារណជន ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

១៤-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

១៥-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១៦-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

**ផ្នែកទី២.ការកំហែងយក**

**១.និយមន័យ**

មាត្រា ៣៦៣ នៃក្រមព្រហ្មទណ្ឌ:អំពើកំហែងយក គឺជាអំពើដែលប្រព្រឹត្តដោយការប្រើហិង្សា ការគំរាមកំហែង ថា នឹងប្រើហិង្សា ឬដោយការបង្ខិតបង្ខំ ដើម្បីទទួលបាននូវ ៖

១-ហត្ថលេខា ឬស្នាមម្រាមដៃ ។

២-ការសន្យា ឬការបោះបង់ចោលអ្វីមួយ ។

៣-ការបង្ហាញអាថិកំបាំងណាមួយ ។

៤-ការប្រគល់មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ ។

ដើម្បីងាយស្រួលកំណត់ធាតុផ្សំបទល្មើស យើងត្រូវសក្យាទៅលើ:

## ២.ធាតុផ្សំបទល្មើស

### ២.១.ធាតុនីត្យានុកូល

មាត្រា ៣៦៤ នៃក្រមព្រហ្មទណ្ឌ អំពើកំហែងយក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ ឆ្នាំនិងពិន័យជាប្រាក់ពី ៤.០០០.០០០ រៀល ទៅ ១០.០០០.០០០ រៀល ។ អំពើកំហែងយក មានស្ថានទម្ងន់ទោស ទាក់ទងទៅនឹងជនរងគ្រោះមាត្រា ៣៦៥ , មានស្ថានទម្ងន់ទោសដោយសារការ ប្រើប្រាស់អាវុធមាត្រា ៣៦៦ , ស្ថានទម្ងន់ទោសដោយសារមានការកាត់អវយវៈ ឬពិការភាព មាត្រា ៣៦៧ , ស្ថានទម្ងន់ទោសដោយសារការធ្វើទារុណកម្ម ឬអំពើឃោរឃៅមាត្រា ៣៦៨ , ស្ថានទម្ងន់ ទោសដោយសារមរណភាពនៃជនរងគ្រោះមាត្រា ៣៦៩ , ការប៉ុនប៉ងមានទោសមាត្រា ៣៧០ និងអាច ប្រកាសទោសបន្ថែមដូចមានចែងក្នុងមាន ៣៧១ នៃក្រមព្រហ្មទណ្ឌ។

### ២.២.ធាតុសត្យានុម័ត

#### ក.អំពើ

-ការកំហែងយកហត្ថលេខាឬស្នាមមេដៃ: ជនល្មើសអាចប្រើប្រាស់ មធ្យោបាយផ្សេងៗដើម្បីកំ ហែងតាមរូបភាពនានា តាមផ្លូវកាយ ផ្លូវចិត្ត គោលបំណងឲ្យជនរងគ្រោះ ផ្តិតមេដៃ ឬហត្ថលេខា ទៅ លើលិខិតណាមួយ ។ ឧទាហរណ៍:ប្រើពាក្យសំដីកំហែងឲ្យជនរងគ្រោះ ផ្តិតមេដៃប្រគល់ដីមួយកន្លែង មកឲ្យខ្លួន បើមិនប្រគល់នឹងគំរាមសម្លាប់ចោល។

-ការសន្យា ឬការបោះបង់ចោលអ្វីមួយ: ជាអំពើកំហែង ឲ្យជនរងគ្រោះធ្វើការព្រមព្រៀងដោយ បង្ខំ ដើម្បីឲ្យជនរងគ្រោះ សន្យា ឬបោះបង់ចោលនូវអ្វីមួយដែល ជនល្មើសចង់បាន។

-ការបង្ហាញអាថិកំបាំងណាមួយ: ជាការគំរាមកំហែង ឲ្យជនរងគ្រោះ ប្រាប់ ឬប្រគល់ឲ្យខ្លួននូវ

ការសម្ងាត់អ្វីមួយអាចជា ឯកសារ សម្លេង ហេតុការណ៍...។

-ការប្រគល់មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ ជាការកំហែង ឲ្យជនរងគ្រោះប្រគល់ឲ្យខ្លួននូវៈ មូលនិធិ របស់មានតម្លៃ ឬទ្រព្យសម្បត្តិ នៅពេលកំណត់ណាមួយ បើជនរងគ្រោះមិនធ្វើតាមនឹងគំរាមបង្កព្យសនកម្មដល់ជីវិត ។

គ្រប់អំពើកំហែងយកកើតមានមុន ទើបអាចមានការប្រគល់ជាក្រោយ។

**ខ.មធ្យោបាយនៃការកំហែងយក**

-ការប្រើហិង្សា

-កាការគំរាមកំហែង ថា នឹងប្រើហិង្សា ឬ

-ដោយការបង្ខិតបង្ខំ

**២.៣.ធាតុអត្តនោម័ត**

ជាអំពើប្រព្រិត្តដោយចេតនា ប្រព្រិត្តដោយជនមានសតិសម្បជញ្ញៈ ក្នុងគោលបំណងចង់បានៈ ហត្ថលេខា ឬស្នាមម្រាមដៃ , ការសន្យា ឬការបោះបង់ចោលអ្វីមួយ ,ការបង្ហាញអាថិកំបាំងណាមួយ, ការប្រគល់មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ ។

**៣.ការផ្តន្ទាទោស**

**៣.១.បទកំហែងយក** (មាត្រា ៣៦៤)

អំពើកំហែងយក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**៣.២.ស្ថានទម្ងន់ទោសបទកំហែងយក**

**ក.ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ** (មាត្រា ៣៦៥)

អំពើកំហែងយក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥ (ប្រាំ) ឆ្នាំទៅ ១០ (ដប់) ឆ្នាំ កាលបើអំពើនេះបានប្រព្រឹត្តទៅលើ ៖

១-បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុអាយុនៃបុគ្គលនោះ ។

២-នារីមានគភ៌ កាលបើគភ៌ ត្រូវបានគេឃើញជាក់ស្តែង ឬកាលបើជនល្មើស បានដឹង ។

៣-បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុនៃជំងឺ ឬពិការភាព កាលបើស្ថានភាពបុគ្គលនេះត្រូវបានគេឃើញជាក់ស្តែង ឬកាលបើជនល្មើសបានដឹង ។

**ខ.ស្ថានទម្ងន់ទោសដោយសារការប្រើប្រាស់អាវុធ** (មាត្រា ៣៦៦)

អំពើកំហែងយក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ កាលបើបទល្មើសនេះប្រព្រឹត្តដោយមានការប្រើប្រាស់អាវុធ ឬដោយ ការគំរាមកំហែងនឹងអាវុធ ។

**គ.ស្ថានទម្ងន់ទោសដោយសារមានការកាត់អវយវៈ ឬពិការភាព**(មាត្រា ៣៦៧)

អំពើកំហែងយក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ ប្រសិនបើអំពើនេះប្រព្រឹត្តមុនពេល ក្នុងពេល ឬក្រោយពេលប្រើហិង្សាដែលនាំឱ្យមានការកាត់អវយវៈ ឬពិការភាពជាអចិន្ត្រៃយ៍ ។

**ឃ.ស្ថានទម្ងន់ទោសដោយសារការធ្វើទារុណកម្ម ឬអំពើឃោរឃៅ** (មាត្រា ៣៦៨)

អំពើកំហែងយក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ប្រសិនបើអំពើនេះប្រព្រឹត្តមុនពេល ក្នុងពេល ឬក្រោយពេលប្រើ ទារុណកម្ម ឬអំពើឃោរឃៅ ។

**ង.ស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ** (មាត្រា ៣៦៩)

អំពើកំហែងយក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ប្រសិនបើអំពើនេះប្រព្រឹត្តឡើង មុនពេល ក្នុងពេល ឬក្រោយពេល ប្រើហិង្សាដែល បណ្តាលឱ្យជនរងគ្រោះស្លាប់ ដោយគ្មានចេតនាសម្លាប់។

**៤.ទោសបន្ថែម** (មាត្រា ៣៧១)

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាសៈ

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្ត នៅក្នុងការប្រកបវិជ្ជាជីវៈ ឬនៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ចំពោះបទឧក្រិដ្ឋ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ចំពោះ បទមជ្ឈិម ។

៤-ការហាមឃាត់ដល់ទណ្ឌិតបរទេសចំពោះការចូល ឬការស្នាក់នៅក្នុងដែនដី នៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយ ដែលប្រើប្រាស់សម្រាប់ប្រព្រឹត្ត បទល្មើស ឬ

ដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៦-ការរឹបអូសវត្ថុ ឬមូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស ។

៧-ការរឹបអូសផលទុន និងទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៨-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុនៅក្នុងទីកន្លែងដែល បទល្មើសនោះបានប្រព្រឹត្ត ។

៩-ការរឹបអូសយានជំនិះរបស់ទណ្ឌិតមួយគ្រឿង ឬច្រើនគ្រឿង ។

១០-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

១១-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

១២-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១៣-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ផ្នែកទី៣.ការគំរាមកំហែងហែកកេរ្តិ៍

### ១.និយមន័យ

តាមមាត្រា ៣៧២ ក្រមព្រហ្មទណ្ឌបានឲ្យនិយមន័យថា: អំពើគំរាមកំហែងហែកកេរ្តិ៍ គឺជាអំពើ

ប្រព្រឹត្តដោយគំរាមកំហែងបើកកកាយ ឬទម្លាក់កំហុសទៅលើអំពើដែលនាំឱ្យប៉ះពាល់ ដល់កិត្តិយស ឬការរាប់អាន ដើម្បី ទទួលបាននូវ ៖

១-ហត្ថលេខា ឬស្នាមម្រាមដៃ ។

២-ការសន្យា ឬការបោះបង់ចោលអ្វីមួយ ។

៣-ការបង្ហាញអាថិកំបាំងណាមួយ ។

៤-ការប្រគល់មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ ។

## ២.ធាតុផ្សំបទល្មើស

### ២.១.ធាតុនីត្យានុកូល

មាត្រា ៣៧៣ នៃក្រមព្រហ្មទណ្ឌ អំពើគំរាមកំហែងហែកកេរ្តិ៍ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០រៀល ទៅ ១០.០០០.០០០រៀល ហើយអំពើនេះមានស្ថានទម្ងន់ទោសដូចជា: មាត្រា ៣៧៤. ស្ថានទម្ងន់ទោសដោយសារការអនុវត្តជាក់ស្តែងនូវការគំរាមកំហែង និងមាត្រា ៣៧៥.ការប៉ុនប៉ងមានទោស ព្រមទាំងអាចប្រកាសទោសបន្ថែមដូចមានចែងក្នុងមាត្រា ៣៧៦ នៃក្រមព្រហ្មទណ្ឌ។

### ២.២.ធាតុសត្យានុម័ត

បទល្មើសគំរាមកំហែងហែកកេរ្តិ៍ស្តែងឡើងតាមរូបភាពពីរគឺ:

-គំរាមកំហែងបើកកកាយ ឬទម្លាក់កំហុស

-ធ្វើឲ្យប៉ះពាល់ដល់កិត្តិយស ឬការរាប់អាន

មានន័យថា ជនល្មើសបានដឹងពីរឿងសម្ងាត់របស់ជនរងគ្រោះ ឬ ដឹងពីចំណុចខ្សោយរបស់ជនរងគ្រោះ រួចធ្វើការគំរាមកមហែងផ្លូវចិត្តជនរងគ្រោះ គោលបំណងឲ្យជ នរងគ្រោះប្រគល់ឲ្យនូវ: ហត្ថលេខា ឬស្នាមម្រាមដៃ , ការសន្យា ឬការបោះបង់ចោលអ្វីមួយ , ការបង្ហាញអាថិកំបាំងណាមួយ , ការប្រគល់មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ ។

ឧទាហរណ៍: បុរសម្នាក់គំរាមកំហែងឲ្យនារីម្នាក់ ប្រគល់ប្រាក់មកឲ្យខ្លួនមួយចំនួន បើមិនឲ្យទេបុរសនោះគំរាមប្រាប់អ្នកជិតខាង ពីរឿងនារីនោះធ្លាប់ដេកជាមួយខ្លួនគន្លងមក។

### ២.៣.ធាតុអត្តនោម័ត

ជនល្មើសប្រព្រិត្តដោយចេតនា ក្នុងគោលបំណងចង់បាននូវ: ហត្ថលេខា ឬស្នាមម្រាមដៃ , ការ

សន្យា ឬការបោះបង់ចោលអ្វីមួយ ,  ការបង្ហាញអាថិកំបាំងណាមួយ,ការប្រគល់មូលនិធិ តម្លៃ  ឬទ្រព្យសម្បត្តិអ្វីមួយ ពីជនរងគ្រោះ ។

**៣.ការផ្តន្ទាទោស**

**ក.អំពីទោស:** ជនល្មើសបានត្រឹមតែគំរាមកំហែង មិនទាន់បង្ហាញរឿងអាថ៌កំបាំង

មាត្រា ៣៧៣. ទោសដែលត្រូវអនុវត្ត

អំពើគំរាមកំហែងហែកកេរ្តិ៍ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២(ពីរ) ឆ្នាំទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**ខ.ស្ថានទម្ងន់ទោស:**ជនល្មើសបានគំរាមកំហែង និងបានបង្ហាញរឿងអាថ៌កំបាំងជនរងគ្រោះ

មាត្រា ៣៧៤. ស្ថានទម្ងន់ទោសដោយសារការអនុវត្តជាក់ស្តែងនូវការគំរាមកំហែង

កាលបើអំពើគំរាមកំហែងហែកកេរ្តិ៍  ឬការទម្លាក់កំហុសដែលនាំឱ្យប៉ះពាល់  ដល់កិត្តិយស ឬការរាប់អាន  ត្រូវបានសម្តែងចេញជាអំពើជាក់ស្តែង ចារីត្រូវ ផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ)  ឆ្នាំទៅ ១០ (ដប់) ឆ្នាំ ។

**៤.ទោសបន្ថែម** (មាត្រា ៣៧៦)

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស:

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្ត  នៅក្នុងការប្រកបវិជ្ជាជីវៈ  ឬនៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ  ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥  ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ  យ៉ាងច្រើន ចំពោះបទឧក្រិដ្ឋ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ចំពោះ បទមជ្ឈិម ។

៤-ការហាមឃាត់ដល់ទណ្ឌិតបរទេសចំពោះការចូល  ឬការស្នាក់នៅក្នុងដែនដី  នៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការរឹបអូសឧបករណ៍ សម្ភារៈ  ឬវត្ថុណាមួយ  ដែលប្រើប្រាស់សម្រាប់ប្រព្រឹត្ត បទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៦-ការរឹបអូសវត្ថុ ឬមូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស ។

៧-ការរឹបអូសផលទុន និងទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៨-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុនៅក្នុងទីកន្លែងដែល បទល្មើសនោះបាន ប្រព្រឹត្ត ។

៩-ការរឹបអូសយានជំនិះរបស់ទណ្ឌិតមួយគ្រឿង ឬច្រើនគ្រឿង ។

១០-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ គ្រប់ប្រភេទ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

១១-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

១២-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១៣-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ផ្នែកទី៤.បទឆបោក

### ១.និយមន័យនៃការឆបោក

អំពើឆបោក គឺជាអំពើបន្លំចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយ ដោយប្រើ ឈ្មោះក្លែង ដោយអះអាងទៅលើឋានៈក្លែង ដោយរំលោភលើឋានៈពិតប្រាកដ ឬ ដោយប្រើឧបាយកលទុច្ចរិត ហើយដូច្នេះបានទទួលពីបុគ្គលនេះ ដែលនាំឱ្យខូច ប្រយោជន៍របស់បុគ្គលនេះ ឬរបស់តតិយជននូវ ៖

១-ការប្រគល់មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ ។

២-ការផ្តត់ផ្គង់សេវា ។

៣-ការធ្វើលិខិតដែលមានតម្លៃជាកាតព្វកិច្ច ឬជាការឱ្យរួចពីកាតព្វកិច្ច ។

## ២.ធាតុផ្សំបទល្មើស

### ២.១.ធាតុនីត្យានុកូល

មាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ អំពើឆបោក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។ អំពើនេះមានស្ថានទម្ងន់ទោសមួយចំនួនដូចជា: មាត្រា ៣៧៩ ស្ថានទម្ងន់ទោសដែលទាក់ទងទៅនឹងជនរងគ្រោះ,មាត្រា ៣៨០ ស្ថានទម្ងន៍ទោសទាក់ទងនឹងជនល្មើស , មាត្រា ៣៨១ ការប៉ុនប៉ងមានទោស ព្រមទាំងអាចប្រកាសទោសបន្ថែមមួយចំនួនដូចមានចែងក្នុងមាត្រា ៣៨២ ។

### ២.២.ធាតុសត្យានុម័ត

អំពើឆបោក ស្តែងឡើងតាមរូបភាពពីរគឺ: ប្រើប្រាស់មធ្យោបាយបន្លំ និងធ្វើខូចប្រយោជន៍ជនរងគ្រោះឬតតិយជន។

**ក.មធ្យោបាយបន្លំ:** ជាមធ្យោបាយដែលធ្វើឲ្យជនរងគ្រោះជឿលើអ្វីមួយ ដោយប្រើប្រាស់អំពើ:

-ការប្រើ ឈ្មោះក្លែង ឬឋានៈក្លែង: ជាអំពើបង្ហាញអត្តសញ្ញាណផ្សេងក្រៅពី អត្តសញ្ញាណរបស់ខ្លួន ឬជាអំពើក្លែងឋានៈរបស់ខ្លួន ខុសពីឋានៈពិតប្រាកដ ក្នុងគោលបំណងទទួលបានផលប្រយោជន៏ពីជនរងគ្រោះ។

-ការប្រើឧបាយកលទុច្ចរិត: ជាមធ្យោបាយ ល្បួងលោម បោកបញ្ឆោត បញ្ចុះបញ្ចូល ទាក់ទាញឲ្យជនរងគ្រោះជឿ ឬសង្ឃឹមលើគម្រោងការប្រឌិតមួយ ក្នុងគោលបំណងទទួលបានផលប្រយោជន៍ពីជនរងគ្រោះ ។

**ខ.ការប្រគល់:** អំពើលួចជនល្មើសដកហូតទ្រព្យសម្បត្តិពីជនរងគ្រោះ ចំណែកអំពើកំហែងយកជនរងគ្រោះប្រគល់ឲ្យទៅជនល្មើសដោយសារជនល្មើសគំរាមកំហែងរីឯអំពើឆបោកវិញជនរងគ្រោះ

ប្រគល់ទ្រព្យឲ្យជនល្មើសព្រោះចាញ់ឧបាយកលជនល្មើស។

**គ.កម្មវត្ថុនៃការឆបោក:** ច្បាប់កំណត់វត្ថុបីប្រភេទគឺ:

-មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ សំដៅទៅលើចលនវត្ថុជារូបីយ។

-ការផ្តត់ផ្គង់សេវា: តាវកាលិកជាសេវាកម្ម

-ការធ្វើលិខិតដែលមានតម្លៃជាកាតព្វកិច្ច ឬជាការឱ្យរួចពីកាតព្វកិច្ច: លិខិតដែលបង្កើត ទទួលស្គាល់ ឬរំលត់កាតព្វកិច្ច ឲ្យខូចប្រយោជន៍។

**២.៣.ធាតុអត្តនោម័ត**

ចារីមានចេតនា ដើម្បីប្រព្រិត្តបទល្មើស ដោយប្រើប្រាស់មធ្យោបាយទុច្ចរិត គោលបំណងទទួលបាននូវការប្រគល់វត្ថុ ឬការផ្តត់ផ្គង់សេវាពីជនរងគ្រោះ។

## ៣.ការផ្តន្ទាទោស

### ក.អំពីទោស

មាត្រា ៣៧៨. ទោសដែលត្រូវអនុវត្ត

អំពើឆបោក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយ លាន) រៀល។

### ខ.ស្ថានទម្ងន់ទោស

មាត្រា ៣៧៩.ស្ថានទម្ងន់ទោសដែលទាក់ទងទៅនឹងជនរងគ្រោះ

អំពើឆបោក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំទៅ ៥ (ប្រាំ) ឆ្នាំ កាលបើអំពើនេះបានប្រព្រឹត្តនាំឱ្យខូចប្រយោជន៍ ៖

១-បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុអាយុនៃបុគ្គលនោះ ។

២-នារីមានគភ៌ កាលបើគភ៌ ត្រូវបានគេឃើញជាក់ស្តែង ឬកាលបើជនល្មើស បានដឹង ។

៣-បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុនៃជំងឺ ឬពិការភាព កាលបើស្ថានភាពបុគ្គលនោះត្រូវបានគេឃើញជាក់ស្តែង ឬកាលបើជនល្មើសបានដឹង។

មាត្រា ៣៨០. ស្ថានទម្ងន់ទោសផ្សេងទៀត

អំពើឆបោក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ កាលបើបទល្មើសនេះបានប្រព្រឹត្ត ៖

១-ដោយអ្នករាជការសាធារណៈ នៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬនៅក្នុងឱកាស នៃការបំពេញមុខងាររបស់ខ្លួន ។

២-ដោយបុគ្គលដែលតាំងខ្លួនជាអ្នករាជការសាធារណៈ ។

៣-ដោយបុគ្គល ដែលធ្វើការអំពាវនាវដល់សាធារណជន ដើម្បីបោះពុម្ពចេញ ឱ្យប្រើប្រាស់នូវមូលបត្រ ។

៤-ដោយបុគ្គលដែលធ្វើការអំពាវនាវដល់សាធារណជន ដើម្បីអង្គាសមូលនិធិ សម្រាប់ជាជំនួយមនុស្សធម៌ ឬសង្គមកិច្ច ។

៥-ជាក្រុមមានការចាត់តាំង ។

**៤.ទោសបន្ថែម** (មាត្រា ៣៨២)

ចំពោះបទមជ្ឈិមដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាច ត្រូវបានប្រកាសៈ

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្ត នៅក្នុងការប្រកបវិជ្ជាជីវៈ ឬនៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ចំពោះបទមជ្ឈិម ។

៤-ការហាមឃាត់ដល់ទណ្ឌិតបរទេសចំពោះការចូល ឬការស្នាក់នៅក្នុងដែនដី នៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលប្រើប្រាស់សម្រាប់ប្រព្រឹត្ត បទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៦-ការរឹបអូសវត្ថុ ឬមូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស ។

៧-ការរឹបអូសផលទុន និងទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៨-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុនៅក្នុងទីកន្លែងដែល បទល្មើសនោះបានប្រព្រឹត្ត ។

៩-ការរឹបអូសយានជំនិះរបស់ទណ្ឌិតមួយគ្រឿង ឬច្រើនគ្រឿង ។

១០-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

១១-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

១២-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១៣-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ផ្នែកទី៥.ការបន្លំ

### ១.និយមន័យ

តាមមាត្រា ៣៨៤ អំពើបន្លំ គឺជាអំពើរបស់បុគ្គលដែលដឹងខ្លួនថាគ្មានលទ្ធភាពដាច់ខាត នឹងបង់ ថ្លៃ ឬដែលសម្រេចចិត្តមិនបង់ថ្លៃ ៖

-ឱ្យគេបម្រើម្ហូបអាហារ ឬភេសជ្ជៈ នៅក្នុងរង្គសាល ភោជនីយដ្ឋានឬនៅក្នុងគ្រឹះស្ថានដទៃទៀត ដែលបើកចំហដល់សាធារណជន ។

-ឱ្យគេប្រគល់បន្ទប់មួយ និងកាន់កាប់បន្ទប់នេះនៅក្នុង សណ្ឋាគារ ឬគ្រឹះស្ថាន ដទៃទៀត ដែលបើកចំហដល់សាធារណជន ។

-ឱ្យគេដឹកជញ្ជូនខ្លួនតាម ត្រីចក្រយាន តាមរថយន្តឈ្នួល ឬតាមមធ្យោបាយដឹកជញ្ជូនផ្សេងទៀត ។

## ២.ធាតុផ្សំបទល្មើស

### ២.១.ធាតុនីត្យានុកូល

មាត្រា ៣៨៤ អំពើបន្លំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ ថ្ងៃ ទៅ ៣ ខែ និងពិន័យជាប្រាក់ពី ១០០.០០០ រៀលទៅ ៥០០.០០០រៀល ហើយមាត្រា ៣៨៥ ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងនៅក្នុងមាត្រាខាងលើនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមខាងលើដែរ ព្រមទាំងមានទោសបន្ថែមមួយចំនួនដូចមានចែងក្នុងមាត្រា ៣៨៦ ក្រមព្រហ្មទណ្ឌ ។

### ២.២.ធាតុសត្យានុម័ត

**ក.អំពើ** អំពើបន្លំស្តែងឡើងតាមរយៈរូបភាពៈ

-អំពើឱ្យគេបម្រើម្ហូបអាហារ ឬភេសជ្ជៈ នៅក្នុងរង្គសាល ភោជនីយដ្ឋានឬនៅក្នុងគ្រឹះស្ថានដទៃទៀត ដែលបើកចំហដល់សាធារណជន ។

-ឱ្យគេប្រគល់បន្ទប់មួយ និងកាន់កាប់បន្ទប់នេះនៅក្នុង សណ្ឋាគារ ឬគ្រឹះស្ថាន ដទៃទៀត ដែលបើកចំហដល់សាធារណជន ។

-ឱ្យគេដឹកជញ្ជូនខ្លួនតាម ត្រីចក្រយាន តាមរថយន្តឈ្នួល ឬតាមមធ្យោបាយដឹកជញ្ជូនផ្សេងទៀត ។

**ខ.មិនព្រមបង់ថ្លៃៈ** ដឹងថាខ្លួនគ្មានលទ្ធភាពតាំងពីដំបូង ប៉ុន្តែសំដែងឲ្យគេជឿថាមានលទ្ធភាព ឬការមិនព្រមបង់ ទៅលើ ថ្លៃម្ហូបអាហារ , ភេសជ្ជៈ , បន្ទប់ស្នាក់នៅ , សេវាដឹកជញ្ជូន ។

### ២.៣.ធាតុអត្តនោម័ត

ជនល្មើសមានចេតនាឬទុច្ចរិត ក្នុងការកេងប្រវញ្ច័ យកទ្រព្យសម្បត្តិ ឬសេវា តាមរយៈការមិនបង់ថ្លៃ។

**៣.ការផ្តន្ទាទោស**

មាត្រា ៣៨៥ អំពើបន្លំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ ថ្ងៃ ទៅ ៣ ខែ និងពិន័យជាប្រាក់ពី ១០០.០០០ រៀលទៅ ៥០០.០០០រៀល។

**៤.ទោសបន្ថែម** (មាត្រា ៣៨៦)

ចំពោះបទមជ្ឈិមដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាច ត្រូវបានប្រកាសៈ

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្ត នៅក្នុងការប្រកបវិជ្ជាជីវៈ ឬនៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ ឆ្នាំ យ៉ាងច្រើន ។

៣-ការរឹបអូសផលទុន និងទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៤-ការរឹបអូសយានជំនិះរបស់ទណ្ឌិតមួយគ្រឿង ឬច្រើនគ្រឿង ។

៥-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៦-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៧-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

**ផ្នែកទី៦.ការរំលោភលើទំនុកចិត្ត**

**១.និយមន័យ**

តាមមាត្រា ៣៩១ នៃក្រមព្រហ្មទណ្ឌ:អំពើរំលោភលើទំនុកចិត្ត គឺជាអំពើគែបំបាត់ មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិ អ្វីមួយ នាំឱ្យខូចប្រយោជន៍អ្នកដទៃ ប្រព្រឹត្តដោយបុគ្គលណាម្នាក់ ដែលគេបាន ប្រគល់ឱ្យបុគ្គលនោះ ហើយបុគ្គលនោះ បានយល់ព្រម ដោយមានភារកិច្ចប្រគល់ សងវិញ បង្ហាញ ឬយកមូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិនោះ ទៅធ្វើការប្រើប្រាស់ ជាកំណត់ ។

## ២.ធាតុផ្សំបទល្មើស

### ២.១.ធាតុនីត្យានុកូល

មាត្រា ៣៩២. អំពើរំលោភលើទំនុកចិត្ត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

មាត្រា ៣៩៣. បទរំលោភលើទំនុកចិត្តពិសេស ដោយអភិបាល ឬបុគ្គលផ្សេងទៀត

គ្រប់អភិបាល ឬអ្នកត្រួតពិនិត្យរបស់នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលមូលនិធិ ឬបុគ្គលដែលត្រូវបានតុលាការ ជ្រើសតាំងឱ្យធ្វើជំនួស នូវកិច្ចការរបស់អ្នកទាំងនេះ ឬនិយោជិត ដែលទទួលអាណត្តិពីនីតិបុគ្គល ដែលប្រព្រឹត្ត អំពើណាមួយដែលជាការរំលោភលើទំនុកចិត្តក្នុងគោលបំណងទទួលផលប្រយោជន៍ ដល់ខ្លួន ឬតតិយជន ឬ ក្នុងគោលបំណងធ្វើឱ្យខូចខាតដល់នីតិបុគ្គល ហើយបាន បណ្តាលឱ្យមានការខូចខាតទ្រព្យសម្បត្តិរបស់នីតិបុគ្គលនោះ ត្រូវផ្តន្ទាទោសដាក់ ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និង ពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

បទប្បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអ្នកជម្រះបញ្ជីរបស់នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលមូលនិធិ ឬ បុគ្គលដែលត្រូវបានតុលាការជ្រើសតាំង ឱ្យធ្វើជំនួសនូវកិច្ចការ របស់អ្នកជម្រះបញ្ជី បានប្រព្រឹត្តអំពើដូចបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ហើយបានបណ្តាលឱ្យមានការខូចខាតទ្រព្យសម្បត្តិ របស់នីតិបុគ្គលនោះ ។

ការប៉ុនប៉ងប្រព្រឹត្តបទល្មើសដែលបានកំណត់ក្នុងកថាខណ្ឌទី ១ និងទី ២ ខាងលើនេះ នឹងត្រូវផ្តន្ទាទោសដូចគ្នាដែរ ។

មាត្រា ៣៩៤.ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនល្មើស

អំពើរំលោភលើទំនុកចិត្ត ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល កាលបើបទល្មើសនេះបានប្រព្រឹត្តឡើង ៖

១-ដោយបុគ្គលណាម្នាក់ដែលបានធ្វើការអំពាវនាវដល់សាធារណជន ដើម្បី ទទួលបានមូលនិធិ ឬតម្លៃសម្រាប់ជាប្រយោជន៍ផ្ទាល់ខ្លួន ឬជាផលប្រយោជន៍របស់ សហគ្រាសឧស្សាហកម្ម ពាណិជ្ជកម្ម

២-ដោយអាណត្តិគាហករបស់តុលាការ ឬអ្នកជំនួយរបស់តុលាការនៅក្នុង ក្របខ័ណ្ឌនៃមុខងាររបស់ខ្លួន ឬនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន ។

៣-ដោយអ្នករាជការសាធារណៈ នៅក្នុងក្របខ័ណ្ឌនៃមុខងាររបស់ខ្លួន ឬនៅ ក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន ។

មាត្រា ៣៩៥.ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងផ្នែកនេះ ត្រូវផ្ដន្ទាទោសដូចគ្នា នឹងបទមជ្ឈិមខាងលើដែរ ។

## ២.២.ធាតុសត្យានុម័ត

បើយើងពិនិត្យទៅលើខ្លឹមសារ នៃមាត្រាខាងលើ យើងឃើញថា បទល្មើសរំលោភលើទំនុកចិត្តមានធាតុប្រាំសំខាន់គឺ:

ក.ការកែបំបាត់:សំដៅទៅលើការកេងចំណេញ ឬកេងយកប្រយោជន៏ពីជនណាមួយតាមរយៈការធ្វើឲ្យម្ចាស់ទ្រព្យបាត់បង់ប្រយោជន៏របស់ខ្លួន ។

ខ.មូលនិធិ តម្លៃ ឬ ទ្រព្យសម្បត្តិអ្វីមួយ: មូលនិធិ សំដៅទៅលើប្រាកកាស ដែលមានតម្លៃអាចចាយវាយបាន។ តម្លៃ សំដៅទៅលើវត្ថុដែលមានតម្លៃ អាចលក់ដូរបាន រួមទាំងឯកសារផងដែរ ។ចំពោះទ្រព្យសម្បត្តិ ជាវត្ថុដែលជាកម្មសិទ្ធិ ។

គ.នាំឲ្យខូចប្រយោជន៏អ្នកដទៃ:សំដៅទៅលើអំពើធ្វើឲ្យបាត់បង់ ឬខូចខាតលាភធនរបស់ជនណាម្នាក់ជាចាំបាច់ ។

ឃ.ទ្រព្យសម្បត្តិ ឬម្ចាស់មូលនិធិបានប្រគល់មកឲ្យខ្លួន: សំដៅទៅលើអំពើ ដែលជនល្មើសបានទទួលពីម្ចាស់នូវៈមូលនិធិ តម្លៃ ឬទ្រព្យ ដោយស្របច្បាប់ តាមរយៈ ការជួល ការតម្កល់ទុក អាណត្តិ ឬការឲ្យខ្ចីប្រើ ។

ង.ជនល្មើសមានកាតព្វកិច្ចសងវិញ ឬប្រើប្រាស់ជាកំណត់ ប៉ុន្តែមិនអនុវត្តតាមលក្ខខណ្ឌ ហើយចាត់ចែង ។

**២.៣.ធាតុអត្តនោម័ត**

បទរំលោភលើទំនុកចិត្ត ជាបទល្មើសប្រព្រឹត្តដោយចេតនាទុច្ចរិត ក្នុងការចាត់ចែង កម្មសិទ្ធិអ្នកដទៃ ដោយខ្លួនមានសិទ្ធិត្រឹមតែ សិទ្ធិកាន់កាប់បណ្តោះអាសន្ន និងបង្កឲ្យខូចប្រយោជន៍របស់ម្ចាស់កម្មសិទ្ធិ។

**៣.ការផ្តន្ទាទោស**

**៣.១.អំពី ទោស**

មាត្រា ៣៩២. អំពើរំលោភលើទំនុកចិត្ត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ១.000.000(មួយលាន) រៀលទៅ ៦.000.000 (ប្រាំមួយលាន) រៀល ។

**៣.២.អំពីស្ថានទម្ងន់ទោស**

**ក.បទរំលោភលើទំនុកចិត្តពិសេស**

មាត្រា ៣៩៣. បទរំលោភលើទំនុកចិត្តពិសេស ដោយអភិបាល ឬបុគ្គលផ្សេងទៀត

ត្រូវផ្តន្ទាទោសដាក់ ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.000.000 (បួនលាន) រៀល ទៅ ១០.000.000 (ដប់លាន) រៀល ។

**ខ.ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនល្មើស**

មាត្រា ៣៩៤.ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនល្មើស

អំពើរំលោភលើទំនុកចិត្តត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំនិង ពិន័យជាប្រាក់ពី ៤.000.000 (បួនលាន) រៀល ទៅ ១០.000.000 (ដប់លាន) រៀល កាលបើបទល្មើសនេះបានប្រព្រឹត្តឡើង ៖

១-ដោយបុគ្គលណាម្នាក់ ដែលបានធ្វើការអំពាវនាវដល់សាធារណជន ដើម្បី ទទួលបានមូលនិធិ ឬ តម្លៃសម្រាប់ជាប្រយោជន៍ផ្ទាល់ខ្លួន ឬជាផលប្រយោជន៍របស់ សហគ្រាសឧស្សាហកម្ម ពាណិជ្ជកម្ម ។

២-ដោយអាណត្តិគាហករបស់តុលាការ ឬអ្នកជំនួយរបស់តុលាការនៅក្នុងក្របខ័ណ្ឌនៃមុខងារ

របស់ខ្លួន ឬនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន ។

៣-ដោយអ្នករាជការសាធារណៈ នៅក្នុងក្របខ័ណ្ឌនៃមុខងាររបស់ខ្លួន ឬនៅ ក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន ។

**៤.ទោសបន្ថែម**

ចំពោះបទមជ្ឈិមដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាច ត្រូវបានប្រកាសៈ

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្ត នៅក្នុងការប្រកបវិជ្ជាជីវៈ ឬនៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ ឆ្នាំ យ៉ាងច្រើន ។

៣-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលប្រើប្រាស់សម្រាប់ប្រព្រឹត្ត បទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៤-ការរឹបអូសវត្ថុ ឬមូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស ។

៥-ការរឹបអូសផលទុន និងទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៦-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុនៅក្នុងទីកន្លែងដែល បទល្មើសនោះបានប្រព្រឹត្ត ។

៧-ការរឹបអូសយានជំនិះរបស់ទណ្ឌិតមួយគ្រឿង ឬច្រើនគ្រឿង ។

៨-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៩-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១០-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ផ្នែកទី៧.ការទទួលផលចោរកម្ម

**១.និយមន័យ**

តាមមាត្រា ៣៩៩ នៃក្រមព្រហ្មទណ្ឌបានឲ្យនិយមន័យថាៈ អំពើទទួលផលចោរកម្ម គឺជាអំពើ

ទទួល លាក់បំបាំង រក្សាទុក ឬបញ្ជូនវត្ថុ អ្វីមួយដោយដឹងថាវត្ថុនោះបានមកពីបទឧក្រិដ្ឋឬបទមជ្ឈិម ។ ត្រូវចាត់ទុកជាអំពើទទួលផលចោរកម្មផងដែរ ៖

-អំពើធ្វើជាអន្តរការីដើម្បីបញ្ជូនវត្ថុអ្វីមួយ ដោយដឹងថារបស់នោះបានមកពី បទឧក្រិដ្ឋ ឬបទមជ្ឈិម ។

-អំពើដែលបានទទួលផលពីផលនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម ដោយបានដឹងហេតុការណ៍ច្បាស់ ។

**២.ធាតុផ្សំបទល្មើស**

**២.១.ធាតុនីត្យានុកូល**

មាត្រា ៣៩៩ និងមាត្រា ៤០០នៃក្រមព្រហ្មទណ្ឌ: អំពើទទួលផលចោរកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និង ពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**២.២.ធាតុសត្យានុម័ត**

-អំពើទទួលយក លាក់បំបាំង រក្សាទុក ឬបញ្ជូនវត្ថុ ឬ អំពើធ្វើជាអន្តរការីដើម្បីបញ្ជូនវត្ថុអ្វីមួយ ឬអំពើដែលបានទទួលផលពីផលនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម

-ដោយដឹងថាវត្ថុនោះបានមកពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ។

**២.៣.ធាតុអត្តនោម័ត**

ជនល្មើស បានដឹងថាវត្ថុនោះបានមកពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ហើយជួយ ទទួល លាក់បំបាំង រក្សាទុក បញ្ជូនវត្ថុ អំពើធ្វើជាអន្តរការីដើម្បីបញ្ជូនវត្ថុអ្វីមួយ ។

**៣.ទោស**

**៣.១.អំពីទោសបទទទួលផលចោរកម្ម**

មាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និង ពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**៣.២.ស្ថានទម្ងន់ទោស**

មាត្រា ៤០១.ស្ថានទម្ងន់ទោស

អំពើទទួលផលចោរកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ)ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ កាលបើបទល្មើសនេះបានប្រព្រឹត្តឡើង ៖

១-ជាទម្លាប់ ។

២-ដោយប្រើប្រាស់ភាពងាយស្រួលដែលការប្រកបសកម្មភាពវិជ្ជាជីវៈផ្តល់ឱ្យ ។

៣-ជាក្រុមមានការចាត់តាំង ។

មាត្រា ៤០២.អតិបរមានៃទោសពិន័យ

អតិបរមានៃទោសពិន័យ អាចស្មើនឹងតម្លៃវត្ថុនៃអំពើទទួលផលចោរកម្ម ។